R. 6 7-11-52

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

## ព្រះរាជាណាចក្រកម្ពុជា

## មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៣

ខែវិច្ឆិកា ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជអាណាចក្រកម្ពុជា

## មន្ទីរស្តីការ ក្រសួងសិក្សាធិការ

## ឧស្សាហាវឌ្ឍី សំរាប់គ្រូបង្រៀន

បញ្ជី រឿង


ទំព័រ

សេចក្ដីណែនាំ ... ... ... ... ... ... ... ... ... ... ... ... ៣

មជ្ឈិមដ្ឋានទី ២ ឧត្ដមដ្ឋាន ភាសា ... ... ... ... ... ... ... ១២

មជ្ឈិមដ្ឋាន ទី ១ ភាសា ... ... ... ... ... ... ... ២០

អាទិកដ្ឋាន ភាសា ... ... ... ... ... ... .. ២២

បរិវច្ចណដ្ឋាន ភាសា ... ... ... ... ... ... ៣១

កុមារដ្ឋាន ភាសា ... ... ... ... ... ... .. ៣៨

តែងសេចក្ដីសម្រាប់ប្រឋមភូមិបំពេញវិជ្ជា ... ... ... ... ... ៤១

តែងសេចក្ដីសម្រាប់ប្រឋមភូមិជាន់ដំបូង ... ... ... ... ... .. ៤៦

អាទិកដ្ឋាន–ទម្ងន់–រង្វាស់រង្វាល់ .. .. .. .. ... .. ... ... ៥១

កុមារដ្ឋាន–ទម្ងន់–រង្វាស់រង្វាល់ ... ... .. ... ... .. ... ៥៨

បរិវច្ចណដ្ឋាន–ទម្ងន់–រង្វាស់រង្វាល់ .. .. .. .. .. .. .. . ៦១

អាទិកដ្ឋាន–វត្ថុស្វាធ្យាយន៍–វិធីបង្ការរោគ .. .. ... ... ... ៦៣

បរិវច្ចណដ្ឋាន–វត្ថុស្វាធ្យាយន៍–វិធីបង្ការរោគ ... .. .. .. . ៦៩

កុមារដ្ឋាន–វត្ថុស្វាធ្យាយន៍–វិធីបង្ការរោគ .. ... .. .. ... ... ៧១

លោកនីតិសម្រាប់គ្រប់ថ្នាក់ ... ... ... ... .. .. .. ... .. ៧៤

មេសូត្រតែមាត់ .. .. .. .. .. .. .. .. .. .. .. .. ៧៦

# សេចក្តីណែនាំ

## ក្បួនច្បាប់ហើយនឹងរបៀបបង្រៀនអំពីការចោទសួរ.-

យើងបានអធិប្បាយក្នុងទស្សនាវដ្តីមុនហើយថា លោកគ្រូបង្រៀនត្រូវជ្រាបច្បាស់ប្រាកដ វិជ្ជាណាដែលលោកយកទៅបង្រៀនកូនសិស្ស ៗ ដើម្បីនឹងបង្រៀនបន្តិចត្រូវលោកគ្រូចេះឲ្យច្រើន ប៉ុន្តែនឹងបានជ្រាបដូច្នេះលោកជាគ្រូបង្រៀនត្រូវជ្រាបវិធីដែលនឹងធ្វើដូចម្តេច ៗ ក្បួនច្បាប់យ៉ាងណាដែលត្រូវប្រព្រឹត្តតាម របៀបយ៉ាងដូចម្តេចខ្លះដែលត្រូវបង្រៀនកូនសិស្សបាននោះផង ៗ នឹងធ្វើឲ្យបានប្រយោជន៍យ៉ាងសំខាន់បំផុតនេះក្នុងមេរៀនទាំងឡាយ ត្រូវកូនសិស្សប្រុងប្រយ័ត្ននេះ ១ ត្រូវស្តាប់លោកជាគ្រូបង្រៀននេះ ១ ត្រូវធ្វើតាមសេចក្តីពន្យល់លោកជាគ្រូគ្រប់ខគ្រប់កន្លែងនេះ ១ ការធ្វើឲ្យក្មេងប្រុងប្រយ័ត្នជាការធ្វើបានដោយកម្រមែនណាស់ ពីព្រោះក្មេងពុំយកចិត្តទុកដាក់ចង់តែងាកទៅឯណេះទៅឯណោះចង់តែនិយាយហើយពុំចង់គិតចំពោះតែការដដែល ៗ យូរពេកផង លោកជាគ្រូត្រូវបំពេញចំណង់ក្មេងឲ្យបានក្រៃពេក គឺត្រូវចោទសួរសិស្ស ការចោទសួរនេះជាផ្លូវនាំ ហើយគាំពារក្មេងឲ្យប្រុងប្រយ័ត្នហើយជាការបំពេញចិត្តក្មេងផង ៗ

ឯការឲ្យកូនសិស្សស្ងៀមស្តាប់គ្រូ ជាការពិតតែពិបាកនឹងធ្វើបាន

ទៅទៀតប៉ុន្តែនឹងធ្វើឲ្យបានឆាយបន្តិចទៅវិញ ត្រូវទម្លាប់ក្មេងឲ្យខំផ្ទៀងស្តាប់គឺការចោទសួរនេះហើយដែលជាប្រយោជន៍ឲ្យក្មេងមានទម្លាប់នោះ ។

ដូច្នេះយើងនឹងអធិប្បាយអំពីការចោទសួរ ហើយនឹងវិធីដែលលោកគ្រូត្រូវធ្វើដូចម្តេចខ្លះ ។

## ប្រយោជន៍ការចោទសួរ

១១.– ពាក្យដែលគ្រូចោទសួរនឹងនាំសិស្សឲ្យនៅនឹង ឲ្យប្រុងប្រយ័ត្នបង្ខំសិស្សឲ្យនិយាយ ឲ្យក្រោកឈរ ឲ្យមានព្យាយាមបន្តិចហើយឲ្យប្រុងផ្ទៀងស្តាប់លោកគ្រូផង កាលណាលោកគ្រូឃើញកូនសិស្សកាយមាយមើលទៅឯណេះឯណោះក្រៅកន្លែងរៀន ឬរាំនិយាយគ្នាឬចង់ដេក នោះលោកគ្រូត្រូវចោទសួរសិស្សនោះភ្លាម ( ចូរឯងថាតាមពាក្យដែលអញនិយាយអម្បាញ់មិញនេះឡើងវិញ) ចូរឯងពន្យល់ពាក្យ. . .( " ពីព្រោះអ្វីបានជាគេធ្វើដូច្នេះ ដូច្នោះ ។ (ល) ។

ពាក្យសួរនេះនាំឲ្យក្មេងរិះគិតតាមប្រាជ្ញា កូនសិស្សគ្រប់គ្នាប្រុងមើលមាត់លោកគ្រូហើយប្រុងឆ្លើយនឹងពាក្យចោទ ដូច្នេះកូនសិស្សចូលគំនិតគិតនាំឲ្យមេរៀននោះធ្វើបានយ៉ាងស្រួលពន់ជាមួយផង កូនសិស្សមិនធុញថប់នឹងមេរៀននោះឡើយ ។

១២.– ចម្លើយកូនសិស្សឆ្លើយត្រូវនឹងគ្រូចោទ ត្រូវឲ្យក្មេងថា

ឡើងវិញប្រយោជន៍ឲ្យនៅចាំជាប់ក្នុងស្មារតីក្មេងពល់គ្នា ។

១៣.— ដល់វេលានឹងបង្រៀនសាឡើងវិញការចោទសួរអាចឲ្យលោកគ្រូជ្រាបបានថាកូនសិស្សបានចំរើនចំណេះដល់ប៉ុននេះ ។ ហើយគឺអាចឲ្យលោកជ្រាបថាការលោកបង្រៀនបានដូច្នេះដូច្នោះ សេចក្ដីនេះលោកនឹងសំគាល់បានថាត្រូវបង្រៀនកន្លែងណា ៗ ឡើងវិញ ក្នុងវិធីនេះការចោទសួរជាប្រយោជន៍ឲ្យផ្សៀងចំណេះកូនសិស្ស ។

១៤.— ការចោទសួរនឹងជួយកូនសិស្សណាដែលមានសេចក្ដីអល់ឯកក្នុងចិត្តឲ្យដឹងច្បាស់ឡើង នាំឲ្យរកសេចក្ដីពិបាកហើយនឹងនាំឲ្យរិះគិតក្នុងសេចក្ដីដែលនិយាយនោះ ។

១៥.— កូនសិស្សធ្លាប់ឆ្លើយយ៉ាងជាក់ច្បាស់នឹងពាក្យសួរយ៉ាងខ្លីហើយងាយផង កូនសិស្សនឹងរឹតតែងាយឆ្លើយទៅទៀត ហើយមានសង្ឃឹមក្នុងចិត្តបន្តិច ។ ឡើងផងវានឹងចេះថា "ខ្ញុំចេះ" ឬ "ខ្ញុំមិនចេះទេ" កាលណាវាថា "មិនចេះទេ" វានឹងដឹងខ្លួនវាជាពុំបានយកចិត្តទុកដាក់ជាប្រាកដ ។

## អំពីការចោទសួរពីរយ៉ាង

ការចោទសួរមានពីរយ៉ាងផ្សេង ៗ គ្នាគឺ

១— ចោទសួរឲ្យកូនសិស្សគិតរកឆ្លើយ

២- ចោទសួរបញ្ជាក់ឡើងវិញ

## ១១- អំពីការចោទសួរឲ្យកូនសិស្សគិតរកចម្លើយ.-

ការចោទសួរនេះបានប្រយោជន៍ឲ្យកូនសិស្សរិះរកចម្លើយឲ្យត្រូវនឹងការដែលលោកគ្រូបង្រៀនដូច្នេះលោកគ្រូត្រូវទម្លាប់កូនសិស្សឲ្យពិនិត្យ ហើយឲ្យនិយាយអំពីអ្វីៗដែលវាឃើញ ហើយវាឃើញយ៉ាងដូចម្តេចអ្វីៗ ដែលវាតូច ឬដែលវាធំក្រិន វាតូចវាធំក្រិនយ៉ាងដូចម្តេច ។ ការចោទសួរនេះនាំឲ្យកូនសិស្សផ្ទឹមពីការណាផ្ទឹមប្រៀបដូចគ្នារបស់អ្វីទាំងពួង ហើយនឹងឲ្យរិះគិតរកហេតុនឹងប្រយោជន៍ដែលបង្កើតឡើងនេះផង ។

## ១២- អំពីការចោទសួរបញ្ជាក់ឡើងវិញ .-

ការចោទសួរនេះមានប្រយោជន៍ ឲ្យលោកជ្រាបថា កូនសិស្សបានចាំហើយបានយល់សេចក្តីគ្រូពន្យល់នោះយ៉ាងដូចម្តេចខ្លះ ត្រូវចោទសួរបញ្ជាក់មុនបង្រៀនមេរៀនកំពុងបង្រៀនហើយនឹងក្រោយបង្រៀន ។

ចោទសួរបញ្ជាក់មុនបង្រៀនមេរៀន- ការចោទសួរមុនបង្រៀនមេរៀនជាការបញ្ជាក់ឲ្យដឹងថាកូនសិស្សបានមើលឬបានរៀនមុននោះឬទេមានប្រយោជន៍មួយយ៉ាងទៀតគឺនឹងបង្រៀនមេរៀនតទៅទៀតឲ្យត្រូវគ្នាឲ្យជាប់គ្នានឹងមេរៀនថ្ងៃនេះ ។

**ចោទសួរបញ្ជាក់កំពុងបង្រៀន.—** ការចោទសួរកំពុងបង្រៀនមេរៀន ត្រូវចោទសួរកាលណាផុតសេចក្ដីមួយឃ្លា ៗ ក្នុងមេរៀននោះ ប្រយោជន៍ឲ្យជ្រាបថាកូនសិស្សបានយល់ៈហើយឬនៅ សេចក្ដីដែលលោកគ្រូបានអធិប្បាយ ឬបានពន្យល់នោះ លោកគ្រូទឹងបង្រៀនតទៅឬទឹងពន្យល់ថែមទៀតក៏បាន លោកជាគ្រូមិនត្រូវនិយាយដកប ៗ ទេ ត្រូវឲ្យសិស្សនិយាយបានយ៉ាងច្រើនវិញ ៗ

**ចោទសួរបញ្ជាក់ក្រោយមេរៀន.—** លោកជាគ្រូត្រូវចោទសួរគ្រប់កន្លែង គ្រប់វយៈក្នុងមេរៀន លោកទឹងជ្រាបថាកូនសិស្សបានយល់សេចក្ដីសព្វគ្រប់ហើយឬនៅ ការចោទសួរនេះក៏អាចឲ្យផ្ទៀងមើលឡើងវិញទៀត ឲ្យភ្ជាប់សេចក្ដីគ្រប់ឃ្លាផ្សេង ៗ ហើយអាចឲ្យងាយចំណាំមេរៀនផង ៗ

## ត្រូវចោទសួរដូចម្ដេច

លោកជាគ្រូត្រូវចេះចោទសួរកូនសិស្ស ឯការចេះចោទសួរនេះមិនងាយដូចជាគិតស្មាននោះទេ ត្រូវឲ្យប្រសប់ណាស់ហើយឲ្យមានប្រាជ្ញាស្រួចណាស់ផង ៗ

ពាក្យចោទសួរយ៉ាងល្អ មានលក្ខណៈដូចមានអធិប្បាយខាងក្រោមនេះ ៗ

១១- ពាក្យចោទសួរត្រូវឲ្យច្បាស់ៗ ត្រូវឲ្យខ្លីហើយងាយផង.-

បើចង់ឲ្យសិស្សឆ្លើយឲ្យបានត្រឹមត្រូវល្អ ត្រូវចោទសួរឲ្យច្បាស់ៗហើយឲ្យខ្លីផង សូមលោកគ្រូសួរកូនសិស្សចំពោះតែពីសេចក្ដីមួយៗ ដូច្នេះលោកជាគ្រូត្រូវរើសរកពាក្យសួរនោះទុកជាមុន វេលាណាដែលលោកប្រុងប្រៀបរៀបមេរៀនមួយៗ លោកគ្រូត្រូវកត់ពាក្យសួរទុកក្នុងសៀវភៅដែលសំរាប់រៀបចំកិច្ចការបង្រៀន ។

ដំពូកមួយទៀតលោកគ្រូចោទសួរឲ្យច្បាស់ៗ កុំថារហ័សឲ្យសោះ ។

១២- ពាក្យចោទសួរត្រូវមានសណ្ដាប់ផ្សេងៗ .-

ពាក្យចោទសួរត្រូវមានសណ្ដាប់តាមមេរៀន ពុំត្រូវចោទសួរអ្វីឲ្យខុស ជាហេតុបន្ទុបកូនសិស្សកុំពុំរកចម្លើយទេ ។ សេចក្ដីនេះត្រូវរៀបចំដោយពិនិត្យពិច័យ ពាក្យចោទដែលត្រូវយកទៅចោទសួរកូនសិស្សនោះដែរ ។

១៣- ពាក្យចោទសួរត្រូវឲ្យល្មមនឹងបំណេះកូនសិស្ស .-

ពាក្យចោទសួរមិនត្រូវឲ្យងាយពេកឬឲ្យពិបាកទេ ។ ពាក្យសួរងាយពេកជាការឥតប្រយោជន៍ហើយគ្មានផលអ្វីសោះពីព្រោះកូនសិស្សមិនចាំប្រឹងនឹងត្រិះរិះ ពាក្យសួរពិបាកពេកកូនសិស្សឆ្លើយពុំរួចរកពុំឃើញឥតអំពើធ្វើដូច្នេះជាការនាំឲ្យតែខាតពេលវេលា ។

១៤– ពាក្យចោទសួរពុំត្រូវឲ្យរួសរាន់ពេកឬយឺតពេកទេ.–

ត្រូវទុកឲ្យកូនសិស្សរិះគិតមុននឹងឆ្លើយ មិនត្រូវបង្ខំឲ្យវាឆ្លើយភ្លាមៗឡើយ ត្រូវមានអធ្យាស្រ័យឲ្យវា ប៉ុន្តែបើមានកូនសិស្សណាយឺតយូរក្រពេកឆ្លើយ ត្រូវចោទសួរពាក្យនោះទៅកូនសិស្សឯទៀតវិញ ។ ទោះជាមិនត្រូវបង្ខំកូនសិស្សឲ្យឆ្លើយភ្លាម ក៏មិនត្រូវទុកឲ្យយឺតយូរពេកណាស់ដែរ ព្រោះជាការស្ងាត់សូន្យតាំងពីលោកគ្រូចោទសួរទៅ ។ កូនសិស្សមិនឆ្លើយដោយសារជួនកាលពាក្យចោទពិបាកពេក ជួនកាលសេចក្តីសួរមិនជាក់ច្បាស់បើដូច្នេះត្រូវផ្លាស់បែបសួរនោះវិញ ។

១៥– តាមច្បាប់ពាក្យចោទសួរត្រូវប្រារព្ធលើកូនសិស្សទាំងអស់គ្នា.– លោកជាគ្រូមិនត្រូវសួរតែកូនសិស្សដែលចេះច្រើនហើយនោះទេ សូមកុំភ្លេចថាលោកត្រូវបង្រៀនក្មេងទាំងអស់គ្នា ទោះជាក្មេងចេះតិចក្តី ក្មេងចេះច្រើនក្តី ក៏លោកត្រូវតែបង្រៀនវា ប៉ុន្តែក្នុងមេរៀនមួយៗ លោកគ្រូគ្មានពេលនឹងសួរក្មេងគ្រប់គ្នាទេ ត្រូវសួរឲ្យបានច្រើនបំផុតតាមការគួរសមល្មមធ្វើបានយ៉ាងតិចណាស់សួរកូនសិស្សឲ្យបានពាក់កណ្តាល លោកត្រូវចាំថា កូនសិស្សដែលមិនបានសួរក្នុងមេរៀននេះ ត្រូវទុកសួរទៅមេរៀនក្រោយទៀត ។

## ត្រូវបៀសវាងសេចក្ដីខុសពីរបីប្រការ

ប្រការ ១.— សូមកុំទទួលចម្លើយមួយម៉ាត់ ៗ ជា "បាទ" ឬជា "ទេ" ចម្លើយនេះបណ្ដាលមកតែពីពាក្យចោទសួរនោះឯងហេតុ សូមលោកកុំភ្លេចថា ចម្លើយកូនសិស្ស ត្រូវឲ្យកើតដោយគំនិតសេចក្ដីគិតខ្លួនរបស់វា ៗ

ប្រការ ២.— សូមកុំព្រមយកចម្លើយមិនត្រឹមត្រូវ បើកូនសិស្សឆ្លើយខុសសូមចោទសួរសេចក្ដីនោះទៅកូនសិស្សម្នាក់ទៀត កូនសិស្សណាឆ្លើយត្រូវហើយសូមឲ្យកូនសិស្សដែលឆ្លើយខុសថាតាមឡើងវិញ ៗ

សូមលោកគ្រូកុំភ្លេចថាលោកគ្រូត្រូវបង្រៀនឲ្យល្មមនឹងចំណេះកូនសិស្ស ពុំមែនឲ្យកូនសិស្សរៀនឲ្យល្មមនឹងចំណេះលោកគ្រូទេ ៗ

ប្រការ ៣.— សូមកុំឲ្យលោកគ្រូផ្ដើមសេចក្ដីឆ្លើយឲ្យសោះ ហើយពុំត្រូវប្រាប់ពាក្យដែលមានក្នុងសេចក្ដីឆ្លើយនោះផង ៗ បើលោកគ្រូផ្ដើមសេចក្ដីឆ្លើយឬប្រាប់ពាក្យដូច្នេះ កូនសិស្សនឹងឆ្គុសប្រហែសហើយនឹងឲ្យរាំខលផង ៗ

## ពាក្យចោទសួររបស់សិស្ស

ប្រយោជន៍បង្រៀនឲ្យបានស្រួលហើយឲ្យបានសប្បាយផង គ្រូឲ្យ

កូនសិស្សបេះស្នួរដែរ លោកគ្រូណាធ្វើធុរៈនឹងបេះទើបបានជាគ្រូប្រាប់ ។ ឯការនេះពិបាកមែនប៉ុន្តែគង់តែនឹងធ្វើបាន សូមលោកគ្រូឲ្យកូនសិស្សផង ។ ស្នួរលោកវិញ នោះកូនសិស្សនឹងមានចំណង់ចង់សួរឡើងពីព្រោះនៅផ្ទះ ក ៗ គឺមែនសួរបងប្អូននឹងឪពុកម្ដាយវាដែរ ឲ្យវាសួរលោកគ្រូអំពីគ្រឿង ៗ ដែលវាពុំដឹង ឬកន្លែងណាដែលវាពុំយល់ ៗ ដោយសារតែហេតុនេះគ្នា ឲ្យបេះបោចសួរយ៉ាងដូច្នេះ លោកនឹងឃើញកូនសិស្សមានចំណង់ចង់ចេះដឹង ចំណង់នេះជាការនាំឲ្យចូលចិត្តមករៀនសូត្រហើយឲ្យវាស្រឡាញ់លោកជាគ្រូផង ។

ល ម៉ាឌិតពុង

ស្រង់ពីកិច្ចសិក្សាបឋមវិជ្ជាបារាំងសែសខេមរ៍ ១ខែអុកតូប្រ៍ឆ្នាំ ១៩៣៣

ភ. ឈ.

## មធ្យមដ្ឋានទី ២

# បបកនឹងដំរី

មានសត្វបបកទាំងឡាយដ៏ច្រើនអាស្រ័យនៅលើកោះមួយកណ្ដាលសាគរ ថ្ងៃមួយនិយាយប្រឹក្សាគ្នាថា យើងជាសត្វអាស្រ័យសាច់សត្វជាភក្សាហារ ស្វែងរកអាហារបានដោយក្រ ទោះជាបានខ្លះសោតក៏ពុំបរិបូណ៌ ហេតុនេះគ្នាយើងគួរតែទៅនិយាយលលួងបញ្ឆោតដំរីសារធំ ឲ្យវាចុះកលយើង ៗ នឹងបានសាច់ដំរីនោះបរិភោគបរិបូណ៌ ។ ហ្វូងបបកគិតឃើញឧបាយមួយហើយទើបនាំគ្នាហែលទឹកទៅកាន់ត្រើយស្ទឹង ចូលទៅកាន់សំណាក់នៃដំរីសារ ដល់ហើយក៏ធ្វើកិរិយាជាអ្នកកោតខ្លាច ឱនសិរសាចុះគំនាប់គោរពដំរី ហើយស្រដីថា បពិត្រលោកជាធំដ៏ប្រសើរសូមលោកមេត្តាប្រោសដល់ពួកយើងខ្ញុំ ដ្បិតយើងខ្ញុំទាំងឡាយសព្វថ្ងៃនេះឥតមាននាយចៅហ្វាយនឹងជួយការពារក្តីអន្តរាយបាន ឥឡូវបានប្រឹក្សាគ្នាឃើញថាព្រះតេជៈព្រះគុណនេះជាសត្វធំឧត្តមសមគួរ ជានាយលើយើងខ្ញុំទាំងឡាយ យើងខ្ញុំប្រគល់កាយជាបាវបំរើព្រះតេជៈព្រះគុណចាប់ដើមពីថ្ងៃនេះតទៅ ។

ឯដំរីសារឥតបញ្ញា បានឮបបកទាំងនោះ មកនិយាយបញ្ឆោតដូចនោះក៏ត្រេកអរស្រះស្រួលទទួលជានាយលើហ្វូងបបក ។

## ពន្យល់ពាក្យ

សាគព= សាគរ – ន. សមុទ្រ

ភក្សាហារ= (ភ័កសាហា) ន. (សំ. ភក្ស=អាហារ–ម. ភក្ខ=ចំណីអាហារឬអាហារជាចំណី )

បពិត្រ= ពាក្យសម្រាប់បព្វជិត ហៅក្សត្រិយ៍ឬសេនាបតី=សូមបពិត្រទ្រង់ជ្រាប ៗ

សទិសសព្ទ: ស្រុះ= ស្រុះស្រួលគ្នា

ស្រុស= ស្រុសមាន់, ស្រុសអន្ទក់

ប្រឹក្សា= ការពិចារណា - ពិគ្រោះគ្នា – ប្រឹក្សាគ្នា

ព្រឹក= ព្រឹកព្រហាម - ព្រឹកស្អែក – ព្រឹកល្ងាច

ព្រឹក្សា= ឈើទាំងពួង – ព្រៃព្រឹក្សា – ពោធិព្រឹក្ស

សួរដោទ – បបកដែលគេនិទាននេះអាស្រ័យនៅទីណា ? ៗ ថ្ងៃមួយបបកទាំងឡាយប្រឹក្សាគ្នាដូចម្ដេច ? ៗ ដំរីទទួលយកអាសាបបកឬទេ ? ៗ ពីព្រោះអ្វី ? ៗ

## បបកនិងដំរី (ត)

ឯបបកទាំងឡាយ ចាប់ដើមពីថ្ងៃនោះមក វានាំគ្នាគោរពបដិបត្តិបំរើ

ដំរីដោយក្ដីមាយា ។ ថ្ងៃមួយបបកនាំគ្នាទៅវន្ទាដំរីស្រដីបបួលថា បពិត្រលោកនាយ ! យើងខ្ញុំទាំងឡាយ អាស្រ័យនៅក្នុងទីព្រៃនេះពុំសប្បាយ ព្រោះរកអាហារបានដោយក្រ យើងខ្ញុំសូមអញ្ជើញលោកនាយឆ្លងទៅឯកោះធំឯណោះ សឹងបរិបូណ៌ដោយទឹក ដោយស្មៅនូវស្លឹកឈើនានា ទោះត្រីសាច់ដែលជាអាហារ សម្រាប់ពួកយើងខ្ញុំក៏មានបរិបូណ៌ យើងខ្ញុំនឹងហែហមឡោមលោកនាយទៅឯកោះនោះ ហើយលោកនាយនឹងបានជាអធិបតីលើពួកយើងខ្ញុំទាំងឡាយ ។ មួយទៀតឯពួកយើងខ្ញុំដែលនៅឯកោះនោះក៏មានច្រើនគ្នា សូមលោកនាយមេត្តាយាត្រាទៅជាកំពូលនៃយើងខ្ញុំ ។

ឯដំរីបានឮពួកបបកពោលពាក្យបញ្ជោរ ព្រមទាំងបញ្ជោតដូចនោះក៏ព្រមតាមទើបនាំបបកទាំងនោះចុះគង្គាហែលឆ្លងមហានទី ឆ្ពោះទៅកាន់កោះធំ ។ បបកទាំងឡាយដឹងថាដំរីសារលុះក្នុងកលខ្លួនហើយ ក៏នាំគ្នាស្រែកលូឡើងបន្លឺសព្ទជាសញ្ញាឲ្យពួកបបកនៅកោះនោះឮ ។

ឯបបកនៅកោះបានឮពួកខ្លួនខាងត្រើយលូឡើងដូចនោះក៏នាំគ្នាលូកងទទួលគ្នា ហើយប្រុងប្រៀបអាត្មាទីទៃៗនឹងចុះហែលទឹកទៅជួយគ្នាខាំដំរីឲ្យលុះក្ដីមរណកាលកណ្ដាលមហានទីនោះឯង ។

ឯដំរីសារស្រវឹងបុណ្យហែលមកដល់កណ្ដាលមហានទីត្រូវទឹកជ្រៅ

ផុតជើងផុតដៃ នឹងអាស្រ័យផ្ទៃផែនដីបាន ក៏អណ្ដែតខ្លួនប៉ុងប៉ោងនៅកណ្ដាលទឹក ឯចចកទាំងឡាយដឹងថាដំរីផុតជើងផុតដៃ នឹងអាស្រ័យព្រេចចាក់តតាំងពុំបានដូចនោះ វាក៏នាំគ្នាហែលឡើងលើខ្នង ខាំកកេរសាច់ពោះដំរីត្រាតែធ្លុះចូលទឹកទៅក្នុងពោះដំរីនោះពេញ ដំរីនោះដល់នូវក្ដីមរណកាលកណ្ដាលគង្គា ពួកចចកវានាំគ្នាបរិភោគសាច់ដំរីតាមសេចក្ដីប្រាថ្នាវាហោង ។

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

( ស្រង់ពីសេចក្ដីសំរាំងលោក ប. ឈុំ )

## ពន្យល់ពាក្យ

វន្ទា= ថ្វាយបង្គំ – សំពះ

នទី= ស្ទឹង – ទន្លេ

ស្រវឹងបុណ្យ= ប្រកាន់មានះ រង្វើងទៅដោយអាងបុណ្យសក្ដិ ។

វេវចនៈ= អធិបតី= អ្នកដែលជាធំ – ជាម្ចាស់លើគេ – ជាប្រមុខ

ឥស្សរៈជន – ចៅហ្វាយ – ចាងហ្វាង

អក្ខរាវិរុទ្ធ: មិត្រ ( ត្រ )– មេត្តា ( ត្តា )– បុណ្យ ( ណ្យ )

សួរដោយ – រឿងនេះបានគតិដូចម្ដេច ? ( ត្រូវមានសាមគ្គីនឹងគ្នា –

ហើយកុំស្រវឹងបុណ្យដូចជាជំរឺ ឃើញគេគោរពហៅព្រះតេជៈព្រះគុណ ក៏ទន់ខ្លួនទាល់តែអស់ជីវិត )

---

ទុក្ខដ្ឋាន

---

## អ្នកប្រាជ្ញវិទ្យាសាស្ត្រ

អ្នកប្រាជ្ញវិទ្យាសាស្ត្រនេះហើយ ដែលលះបង់ពេលវេលាប្រឹងស្រាវជ្រាវរាវរក គិតធ្វើរបស់ប្លែក ៗ ឡើង ដើម្បីជាប្រយោជន៍ដល់មនុស្សផងគ្នា ៗ តែដោយហេតុមនុស្សនៅមានលោភ ក្រោធ វង្វេង ជាប់នៅខាងក្នុងខ្លួនសន្ដាន មិនគិតធ្វើចំពោះរបស់ដែលមានប្រយោជន៍ដល់មនុស្សផងគ្នាតែម៉្យាងទេ គឺនាំគ្នាសាងគ្រឿងប្រហារមនុស្សនិងវត្ថុដែលមនុស្សខំកសាងឡើង ឲ្យហិនហោចខូចខ្ចីទៅទៀតផង ហេតុដូចនេះបានជាយើងមើលឃើញចម្បាំងសម័យនេះ មានអាកាសយាន៍សំបើមដូចជាគ្រាប់បែក កាំភ្លើងតូចធំរទេះអណ្ដើកប៉មបន្ទាយកប៉ាល់ចម្បាំងធំ ៗ នឹងកប៉ាល់មុជទឹក មេដែក គ្រាប់បែកបណ្ដែតក្នុងទឹកពាក់ជ្រៅ យន្ដហោះចម្បាំងទំនើបថ្មី គ្រឿងផ្ទុះ បញ្ចាំងយន្ដហោះ គ្រឿងស្ដាប់សម្លេងយន្ដហោះ កប៉ាល់ពិឃាតក៏ប៉ាល់មុជទឹកបែបថ្មីនិងវត្ថុដទៃ ៗ ទៀតច្រើនជាអនេក ៗ ឃើញថាសង្គ្រាមក្នុងបច្ចុប្បន្ននឹងអនាគតនោះ

មានអាការសាហាវមុខគួរស្អប់ស្អើមជាទីបំផុត ។ គ្រឿងប្រហារអស់នេះក៏កើតឡើង ដោយសារស្នាដៃនៃអ្នកប្រាជ្ញវិទ្យាសាស្ត្រ ដូច្នេះទើបយើងមើលឃើញច្បាស់ថា របស់ណាដែលមានគុណច្រើនឥតបើគណនា របស់នោះក៏មានទោសធ្ងន់ដែរ ។

(ស្រង់សេចក្តីសំរាំងលោក ច-ឈុំ)

## ពន្យល់ពាក្យ

គ្រោធ = កំហឹង

ប្រហារ = កាប់សម្លាប់-ពិឃាត-វាយ

អនេក = (អៈនេក) = ច្រើនក្រៃ-រាប់ពុំអស់

បច្ចុប្បន្ន – ពេលឥឡូវនេះ

អនាគត = កាលឬសម័យខាងមុខ

ររបនៈ = ចម្បាំង-សង្គ្រាម-សឹក.ការតយុទ្ធ

អក្ខរាវិរុទ្ធ: ប្រណិប័តន៍ – បដិបត្តិ ឬ ប្រតិបត្តិ

ប្រណិប័តន៍ = (ន.) ការសំដែងសេចក្តីគោរព – ការគំនាប់ឬ

សំពះសូមក្រាបប្រណិប័តន៍ ចូលមកលោក ....

បដិបត្តិ ឬ ប្រតិបត្តិ = (មគធៈនិងសំស្ក្រឹត) – ការប្រព្រឹត្ត–

កាន់–ធ្វើតាម–

## សេចក្ដីបដិបត្តិ—ត្រូវប្រតិបត្តិតាមច្បាប់

សួរចោទ — អ្នកប្រាជ្ញវិទ្យាសាស្ត្រ បានបង្កើតអ្វីខ្លះដល់មនុស្សផងគ្នា ? តើព្រោះអ្វីបានជានាំគ្នាសាងគ្រឿងប្រហារមនុស្ស ? ចម្បាំង ២ ដងនេះមានអាការដូចម្ដេចខ្លះ ? គ្រឿងប្រហារអស់នេះ កើតឡើងដោយសារគុណណា ? យោបល់អ្នកយល់ឃើញដូចម្ដេច ?

## សេចក្ដីចំរើននៃវិទ្យាសាស្ត្រ

មនុស្សដែលបានទទួលការសិក្សាមកហើយ តែងសង្កេតឃើញច្បាស់ថា ស្រុកទេសក្នុងសម័យមុននឹងសម័យឥឡូវនេះ មានសភាពខុសគ្នាឆ្ងាយណាស់ ទាំងគ្រឿងប្រើប្រាស់សព្វគ្រប់ប្រការ ទាំងយានជំនិះ ទាំងគ្រឿងសំលៀកបំពាក់ទាំងគេហស្ថាន រហូតដល់អាហារភោជន គឺថាសព្វសារពើទាំងអស់ក្នុងលោក តែងមានអាការប្រែប្រួលផ្លាស់រូបផ្លាស់សភាពដើមទៅទាំងអស់ ។ ផលនៃសេចក្ដីប្រែប្រួលនេះ មកអំពីវិទ្យាសាស្ត្រចំរើនឡើងយ៉ាងសំបើម ដើម្បីធ្វើឲ្យលោកនេះផ្លាស់រូបរាងស្ទើរតែមិនស្គាល់យ៉ាងច្បាស់ណាស់ ដូចជាពីដើមមានតែរទេះគោក្របី ឬរទេះសេះ ឥឡូវកែប្រែទៅជារថយន្ត រថភ្លើង ពីដើមមានតែ ទូកចែវ ទូកអុំ ទូកក្ដោង ឬសំពៅកេត្រា ឥឡូវមានកប៉ាល់តូចធំបើកចេញទៅក្នុង

មហាសមុទ្រឥតញញើតនឹងខ្យល់ព្យុះ ។ សម័យនេះការគមនាគមន៍ចំរើនឡើងយ៉ាងរួសរាន់ ការទៅមកកាន់គ្នាក្តី ការជូនដំណើរដល់គ្នាក្តី សឹងរហ័សឆាប់ទាន់ចិត្តលើសសម័យដើមឆ្ងាយណាស់ ព្រោះយើងមានវិទ្យុ វិទ្យុទោរសព្ទ វិទ្យាទោរលេខ នឹងមានដំនិះទំនើបថ្មី ដូចជារថយន្ត រថភ្លើង នឹងយន្តហោះជាដើម សុទ្ធតែរបស់កើតថ្មីទាំងអស់ ។

បណ្តាវត្ថុដែលគេគិតប្រឌិតធ្វើឡើងទាំងប៉ុន្មាន សុទ្ធតែនាំឲ្យបានស្រួលបានសប្បាយ បានសេចក្តីសុខក្សេមក្សាន្តដល់មនុស្សយើងទាំង-អស់នេះ ជាផលដែលកើតមកអំពីសេចក្តីចំរើនតាមផ្លូវវិទ្យាសាស្ត្រ ។

(ស្រង់ពីសេចក្តីសំរាំងលោក ប. ឈុំ)

## ពន្យល់ពាក្យ

វិទ្យាសាស្ត្រ = វិជ្ជាដែលគេរកឃើញ ដោយការលៃផ្សំមាន ការផ្សំធាតុជាដើម ។

អាគារ = សភាព-បែបបទ ។

កេត្រា = សំពៅ

គមនាគមន៍ = ការកាន់គ្នាទៅវិញទៅមក

ប្រឌិត = តាំងឡើងផ្តើមឡើង

សទិសនាម: សព្វ = ទាំងពួង–គ្រប់-ទេះសព្វ

សប់ = សប់ទឹក–ប្រសប់ការ

សប្បុសប្ត = យល់សប្ត

សព = ខ្មោច បូជាសព

សួរទោទ– ស្រុកទេសឥឡូវនេះ មានសភាពខុសពីសម័យមុន យ៉ាងដូចម្ដេចខ្លះ? ផលដែលបណ្ដាលឲ្យប្រែប្រួលមកអំពីអ្វី ៗ ពីព្រោះបានជាការទៅមកកាន់គ្នាឆាប់រួសរាន់ជាងពីដើម ៗ ការដែលគេតាំងផ្ដើមឡើងតាំងប៉ុន្មានមានប្រយោជន៍ឬទេ? ពីព្រោះអ្វី ៗ

---

មជ្ឈមដ្ឋានទី ១

## រៀនមើល – សរសេរតាមសូត្រ

## និយាយអំពីជំនួញ

នៅប្រទេសខ្មែរ របរជំនួញធ្លាក់ទៅលើជនបរទេសស្ទើរតែទាំងអស់ ៗ ចិនប្រសប់ធ្វើជំនួញណាស់ ចិនម៉ៅទំនិញយក ដើម្បីនឹងលក់ទៅវិញឲ្យបានថ្លៃច្រើន ៗ

មានអ្នកជំនួញជាតិចិននៅគ្រប់កន្លែង តាំងពីទីក្រុងរហូតទៅដល់ភូមិតូច ៗ នៅស្រុកស្រែចំការ ៗ គេឃើញមានចិនរកស៊ីធ្វើជំនួញគ្រប់

មុខ ខ្លះជាអ្នកជំនួញស្រូវ ពោត ម្រេច ក្រវាញ ស្បែក ស្នែង ត្រី ខ្លះទៀតមានផ្ទះលក់ទំនិញផ្សេងៗ ខ្លះទៀតជាអ្នកបោកអ៊ុតខោ អាវ ខ្លះទៀតជាអ្នកទិញហើយលក់របស់ចាស់ៗ ខ្លះទៀតជាក់ពានលក់របស់ឡាយឡុង ខ្លះទៀតធ្វើជាងមាស ជាងឈើ ជាងកំបោរ ជាងកាត់ដេរខោអាវ ជាងដេរស្បែកជើង ខ្លះទៀតជាអ្នកម៉ៅការសង់ផ្ទះ ធ្វើស្ពាន លើកថ្នល់ ។ល។

ចិនប្រវ័ញ្ចន៍ខ្មែរយកផលដំណាំ ដោយឲ្យថ្លៃថោកណាស់ ហើយយកផលដំណាំនោះទៅលក់បានចំណេញច្រើន ។

ហេតុនេះគួរតែជនជាតិខ្មែរ រៀនឲ្យស្គាល់មុខរបរជំនួញដើម្បីកុំឲ្យចិនបោកបាន ។

ពន្យល់ពាក្យ .– ជំនួញ= មុខការរបរដែលជួញ, របស់ដែលគេជួញ ។ របរជំនួញ = របរខាងការជួញ ។ ប្រសប់ = គ. ថ្នឹក ប៉ិន ប៉ិនខាងស្ទង់ លៃ គ្នេរ ។ ម៉ៅ= កិ. រ៉ូបរ៉ូមទាំងស្រុង ។ ប្រវ័ញ្ចន៍= កិ. (អ. ថ. ប្រវាញ់) បញ្ឆោត បោកប្រាស់ ។

ពាក្យសួរ .– នៅប្រទេសខ្មែរមានរបរជំនួញច្រើនដែរឬទេ? របរជំនួញនោះធ្លាក់ទៅលើជនជាតិណា? ខ្មែរចូលចិត្តរកស៊ីធ្វើជំនួញឬទេ ព្រោះអ្វី? ហេតុអ្វីបានជាចិនចូលចិត្តធ្វើជំនួញណាស់? ព្រោះអ្វីបានជា

ចិនមានភោគសម្បត្តិច្រើនជាងខ្មែរ ? ខ្មែរយើងត្រូវធ្វើដូចម្តេចកុំឲ្យចិនបោកបាន ?

ពាក្យទំនិមទំនៀមថា ចេះមកពីរៀន មានមកពីរក ។

---

## អាទិតក្ខដ្ឋាន

## បង្រៀនមើល-បង្រៀនពាក្យ

### អាទិត្យទី ១- ក្មេងចេះធ្វើឲ្យឪពុកម្ដាយសប្បាយចិត្ត

( សៀវភៅវិជ្ជាខេមរភាសា អាទិកដ្ឋានទំព័រទី ១ )

នាម.- ឪពុក ក្បាល សៀវភៅ ទំព័រ មេរៀន សត្វចាប សំឡេង បង្អួច ដើមត្របែក ប្រក់ផ្ទះ រូប ខ្នង ។

គុណនាម.- ក្រាស់ ខ្ចី វែង ស្តើង ពីរោះ ទុំ ក្រហម ក្រ-អូប ល្អ ទោរទន់ ។

កិរិយាសព្ទ.- ឱនក្បាលចុះ ខំមើលមេរៀន យំសំឡេងពីរោះ ស្ដាប់សំឡេងចាបយំ លេងរូប បង្ហើរខ្លួន ស្រែក សើច ធ្វើជាមិនដឹង

ពន្យល់ពាក្យ - ធ្វេស = ធ្វោយ ប្រហែស ធ្វេសស្មារតី

ធ្វើគំនិត ។ ក្បែរ = ជិត ។ មិនរើស = មិនអើពើ ។ ទោរ = កោងទ្រេត ។ ប្រកផ្ទះ = ចន្លោះផ្ទះ ។ ពីរោះ = សំឡេងគាប់ត្រចៀកគួរឲ្យចង់ស្ដាប់ ។

បទវេយ្យាករណ៍ — ប្រាប់ ស្ដាប់ ផល់ ចង់ ចប់ អស់ (មានសញ្ញាបន្តក់លើស្រៈ អា អ) ។

ហាត់ភាសា .— ក្នុងរឿងនេះគេនិយាយពីអ្វី? ចាបជាសត្វដូចម្ដេច? ចាបក្នុងរឿងនេះវាទំនៅឯណា? ដើមត្របែកនោះនៅឯណា? មានអ្វីនៅលើដើមត្របែក? មានអ្វីនៅប្រកបន្ទោះផ្ទះ? ចៅងួនមានចិត្តចង់ស្ដាប់សំឡេងចាប បេះត្របែកទំ បង្ហើរខ្លួន លេងវ៉ូវដែរឬទេ? ព្រោះអ្វី?

## ២— ត្រូវមកសាលារៀនឲ្យទាន់ពេលវេលា

សៀវភៅដែលទំព័រ ទី ២

ពាក្យនឹងភាសា សូមធ្វើដូចមេរៀនមុន

### វិធីហាត់សរសេរ

ចូរធ្វើជាឃ្លានឹងពាក្យខាងក្រោមនេះ ៖

សាលារៀន - ស្ដារ - រៀន - យឺតយូរ

ឧទាហរណ៍.— ខ្ញុំទៅសាលារៀនរាល់ថ្ងៃ ។ នៅសាលារៀនខ្ញុំ

មានស្គរមួយ ។ ខ្ញុំរៀនឲ្យបានទៀងទាត់ ។ ខ្ញុំប្រឹងដើរឲ្យលឿន ដើម្បីកុំឲ្យទៅឲ្យដល់សាលារៀនយឺតយូរ ។

ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖

សិស្សមិនត្រូវមកសាលារៀនឲ្យ . . . ពេកឬឲ្យ . . . ពេកទេ

សិស្សត្រូវមកសាលារៀនឲ្យ . . . ម៉ោង ហើយមិនត្រូវប្រឡែងគ្នាលេង...... ( នៅកណ្ដាលផ្លូវទេ ) ។

## សរសេរតាមសូត្រ

សូមជ្រើសយកសេចក្ដីកថាមេរៀន ដែលបានជ្រៀនមើលខាងលើនេះចំនួនបួនប្រាំបន្ទាត់មកឲ្យសិស្សសរសេរតាមគ្រូថាផង ។

## តែងសេចក្ដី

ចូរអធិប្បាយអំពីសិស្សខ្សោយរៀនសូត្រណាម្នាក់ ដែលអ្នកបានស្គាល់ពិតប្រាកដ ។

ផ្នត់តែង

១- សេចក្ដីផ្ដើម ៖ អ្នកបានស្គាល់សិស្សណាម្នាក់ដែលឧស្សារៀនសូត្រឬទេ ?

២- សេចក្ដីរាប់រៀប ៖ សិស្សនោះឈ្មោះអ្វី ? អាយុប៉ុន្មានឆ្នាំ ? វារៀននៅថ្នាក់ណា ? វាចាំមេទន្ទេញឬទេ ? វាធ្វើដូចម្ដេចខ្លះនៅក្នុងសាលារៀន នៅផ្ទះ ? ។

៣- សេចក្ដីបញ្ចប់ ៖ យោបល់របស់អ្នក ។

អក្សរផ្ចង់

ក ភ គ ត ធ ត្ដៀ

ភ ភា ភិ ភី ភូ ភួ ភើ ភេ ភៃ ភោ ភុំ ភុំភឿន រត់រកភួយ

កុំភិតភ័យអី ។

បង្រៀនពាក្យហាត់ភាសា

អាទិត្យទី ២ - អំពីក្រុមញាតិ

នាម: ឪពុក ( បិតា ) មាតា ( ម្ដាយ ) កូន បង ប្អូន កូនច្បង -

កូនបន្ទាប់ កូនពៅ កូនទី កូនប្រុស កូនស្រី រៀមច្បង ក្រុមញាតិ ញាតិសន្តាន ។

គុណនាម= ក្មេង ចាស់ តូច ធំ កម្លោះ ក្រមុំ ជំទង់ ។

កិរិយាសព្ទ= កើតកូន សម្រាលកូន ឆ្លងទន្លេ ប្រសូត ថែទាំ បីបាច់រក្សា ចិញ្ចឹមកូន បំបៅកូន ផ្តេកកូន ផ្ងូតទឹក បញ្ចុកបាយ ពកូន ។

ហាត់ភាសា– ក្រុមញាតិអ្នកមានមនុស្សប៉ុន្មាននាក់? មាតាបិតាអ្នកអាយុប៉ុន្មានឆ្នាំហើយ? អ្នកមានបងប្អូនប៉ុន្មាននាក់? ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន? ឈ្មោះណាជាកូនច្បង? កូនពៅឪពុកម្តាយអ្នកប្រុសឬស្រី? យ៉ាងដូចម្តេចដែលហៅថាកូនកម្លោះ? កូនក្រមុំ? កូនជំទង់? កាលណាប្អូនអ្នកយំ អ្នកធ្វើដូចម្តេច? ម្តាយអ្នកធ្វើដូចម្តេច? រាល់ថ្ងៃឪពុកម្តាយអ្នកធ្វើអ្វី? ដើម្បីអ្វី? អ្នកត្រូវធ្វើដូចម្តេចនឹងឪពុកម្តាយអ្នក នឹងបងប្អូនអ្នក? ។

**បង្រៀនមើល**

## ១– នៅជួបជុំក្រុមញាតិក្នុងវេលាយប់

(សៀវភៅវិជ្ជាខេមរភាសាបរិណាបដ្ឋានទំព័រលេខ ៤៦)

## ២-សេចក្ដីស្នេហានឹងបងប្អូនបង្កើត

សៀវភៅវិជ្ជាខេមរភាសាអធិកដ្ឋានទំព័រលេខ ៩ )

ពន្យល់ពាក្យក្នុងមេរៀនទី ១– អាស្រ័យ = ស៊ី - ទទួលទាន បរិភោគ ។ ព្យួរនៅពិតាន (អ.ថ.ពិដាន)= ផ្ដក់នៅប៉ាំងក្រោមដំបូល ។ ដេញចាប់=កែ ត្រែះខ្សែដង្រ្គី ។ និទានរឿងព្រេង=និយាយ ឬសំដែងរឿងដែលមានមកជាយូរអង្វែងហើយ ។

ក្នុងមេរៀនទី ២ – ជម្ងឺ ឬជំងឺ= សេចក្ដីឈឺចាប់ អាពាធ រោគ ។ ដណ្ដាំបបរ= ចំអិនបបរ ។ ផ្កាភ្លើង= កំទេចភ្លើងដែលព្រាយចេញ ឬ ហើរចេញព្រោងព្រាត ។ បាវព្រាវ= មនុស្សអ្នកខ្សត់ខ្សោយទន់ទាប ឥតមានទីពុំនាក់ ដែលចូលមកជ្រកអាស្រ័យនៅផង, ជាអ្នកធ្វើកិច្ចបំរើដូចបាវ ។

**សរសេរតាមសូត្រ**

សៀវភៅដដែលទំព័រ ៩ តាំងពីបន្ទាត់ទី ១ រហូតដល់ហេតុអ្វីបាន ជាប្អូនទៅធ្វើឲ្យនឿយលំបាកខ្លួនឯងយ៉ាងដូច្នេះ ខ្ញុំអ្វីបាវព្រាវនៅក្នុងផ្ទះៗ

អក្ខរាវិរុទ្ធ= ស្នេហា (ស្នេហា) ប្អូន (បដើងអ) បង្កើត (ព្យាង្គតម្រួត)

ដម្បី (ម. ជំនួសនិគ្គហិត "-ំ") ។ បបរ ( រ ) ហើរ ( រ ) ក៏ ( ៏ ) បទ

វេយ្យាករណ៍= សញ្ញាបន្តក់ ( ់ ) ប្រើតែលើពាក្យដែលកើត ពីស្រៈអ.អា ហើយសព្ទខ្លី ។

ឧទាហរណ៍= ដល់, ម្នាក់, ចាស់, ស្រឡាញ់, ណាស់, ស្រាប់ៗ អក្សរដែលទទួលបន្តក់បាន ៖ ក ង ប ញ ត ន ប ល ស ។

## តែងសេចក្តី

នៅក្នុងខែដំបូង គ្រូបង្រៀនសិស្សឲ្យចេះរកចំនងតែង ឲ្យតែងតាម មើលសង្កេតរូបគំនូរ ។

### អំពីនៅជួបជុំក្រុមញាតិនៅវេលាយប់

( សៀវភៅវិជ្ជាខេមរភាសាបរិច្ចណដ្ឋានទំព័រ ៤៧ )

### ចំណងតែង

១- សេចក្តីផ្តើម ៖ ក្នុងរូបភាពនេះមានមនុស្សប៉ុន្មាននាក់ ? ហើយមានអ្វីព្យួរនៅពីលើ - មនុស្សទាំងអស់នេះគឺអ្វី ?

២- សេចក្តីរៀបរាប់៖ នៅចុងតុៈខាងស្តាំមានអ្វី - ស្លៀកពាក់

ដូចម្ដេច - អង្គុយលើអ្វី - ធ្វើអ្វី ? អ្នកណាអង្គុយនៅខាងឆ្វេងគេ - ធ្វើអ្វី ? ធ្វើដៃដូចម្ដេច ? ហើយនៅខាងមុខមានអ្នកណាខ្លះឈរ ? ធ្វើអ្វី ? នៅបន្ទាប់ហើយខាងស្ដាំដៃមានអ្នកណា ? ឈរឬអង្គុយ ? ម្ដាយកំពុងធ្វើអ្វី- ហើយនៅខាងចុងបំផុតមានអ្នកណា ? ។ អង្គុយធ្វើអ្វី ?

៣- សេចក្ដីបញ្ចប់ ៖ អ្នកយល់ឃើញដូចម្ដេចអំពីគ្រួសារនេះ? ព្រោះអ្វី ?

អានិត្យទី ៣- ១កូនលុះដំបូន្មានមាតាបិតា

( សៀវភៅវិជ្ជាខេមរភាសាអចិកដ្ឋានទំព័រ ៣២ )

២-វត្តប្រតិបត្តិប្រសើររបស់កូន

( សៀវភៅដដែលទំព័រ ៣៨ ) ។

៣- បងប្អូនល្អ ( សៀវភៅដដែលទំព័រ៤៤ ) ។

ពន្យល់ពាក្យក្នុងមេរៀនទី ១- លុះដំបូន្មាន= ធ្វើតាមពាក្យប្រដៅ ( ស្ដាប់ដំបូន្មាន ) ។ ម្នីម្នា — រវៀសរវៃ - រូតរះ - រួសរាន់ ប្រញាប់ប្រញាល់ ។

ពន្យល់ពាក្យក្នុងមេរៀនទី ២ — ដើងញ្ញាយព្យុះ—ធ្លុតពពកស វែងឆ្ងាយ ធ្លុកជាមួយនឹងពពកឯទៀត ។ ថែទាំ = ថែរក្សាប្រយ័ត្ន

មិនប្រហែសធ្វេស (ថែញឹកញយ) ធុញថប់ = ទញ់ទាល់ក្នុងចិត្ត, ជិនឆ្អន់, នឿយណាយរសាយចិត្ត ។ ប្រតិបត្តិ ឬ បដិបត្តិ – ការប្រព្រឹត្តកាន់ ធ្វើតាមច្បាប់ ។

## វិធីហាត់សរសេរ

ចូររកវេវចនៈនៃពាក្យ ៖ ញាប់ព្រាវ–ព្យាយាម–ម្នីម្នា ។

ចូររកពាក្យផ្ទុយនៃពាក្យ ៖ ស្រឡាញ់ សប្បាយចិត្ត–ទំនៀម ។

## សរសេរតាមសូត្រ

សូមយកសេចក្ដីបង្រៀនមើលខាងលើនេះមកដាក់ឲ្យសិស្សសរសេរតាមគ្រូថាផង (សូមធ្វើដូចអាទិត្យមុន) ។

## អក្សរផ្ចង់

ក ភ គ ត តិ ត្បៀ ត តា

តី តូ តួ តើ តឿ តេ តោ តៅ តុ តំ

តុទូ តុំកំបោរ តាតូបតែងតួ វែកតោក ។

អាទិត្យទី ៤- (សូមសាបង្រៀនពីដើមឡើងវិញ)

មជ្ឈិមដ្ឋាន

# រៀនពាក្យ ហាត់ភាសា

អាទិត្យទី ១-

## ១- អំពីអាហារ

នាំសិស្សនិយាយ ៗ ជីវិតមនុស្សយើងរស់ដោយសារអ្វី? យើងបរិភោគអ្វីជាអាហារ? បាំងអាស្រ័យបាយដូចយើងឬទេ? គេបរិភោគអ្វី? សាសន៍ណាខ្លះដែលបរិភោគបាយដូចខ្មែរយើង? (ល)

បង្រៀនពាក្យ- ឯបង្រៀនពាក្យនេះគឺឲ្យសិស្សស្គាល់ពាក្យនោះប្រាកដ ហើយឲ្យចេះយកពាក្យទាំងនោះ មកនិយាយធ្វើជាឃ្លាបានផង ម្យ៉ាងទៀតឲ្យសិស្សស្គាល់ច្បាស់ថាពាក្យនេះកើតមកពីពាក្យអ្វី ឧបមាដូចពាក្យ សម្ល គឺកើតមកពីពាក្យស្ល ចង្អើរ កើតមកពីពាក្យផ្អើរ ៗល ៗ ដើម្បីនឹងឲ្យសិស្សរកពាក្យដែលឫសគល់ដូចគ្នាទាំងនេះ យើងត្រូវសួរពីសណ្ដានគឺថាពាក្យ ដំណើរ កើតមកពីពាក្យអ្វី ៗ ពាក្យដើរ កើតបានជាពាក្យអ្វីខ្លះ ៗល ៗ

នាម- បាយ បំណី អាហារ នំប៉័ង សម្ល បន្លែ ត្រីអាំង ត្រីផ្អើរ ត្រីងៀត អន្លក់ ញាំក្ដា ត្រីខ ត្រីចៀន

គុណនាម– ជ្រាយ ស្រួយ ស ជូរផ្អែម ប្រៃ សាប ស្អិត ខ្ទាប ឆៅ

កិរិយាសព្ទ– ដាំបាយឆ្អិន ទិញចំណី ស្ល សាច់ជ្រូក ឆ្អើរត្រី

ហាត់សរសេរ– ចូរបំពេញសេចក្ដីខាងក្រោយនេះនៅកន្លែងចន្លោះ

ខ្មែរចិនយួនមិនបរិភោគ ....... ដូចបារាំងទេ គឺអាស្រ័យ ...... ជាអាហារ ។ យើងមិនត្រូវបរិភោគ ...... ឆៅទេពីព្រោះអាហារឆៅនាំបណ្ដាលឲ្យកើត ...... ។

២– អំពីសត្វស្រុកដែលយើងយកសាច់ជាអាហារបង្រៀនភាសានាំឲ្យសិស្សនិយាយ ។ ក្រៅពីត្រីអ្នកអាស្រ័យសាច់អ្វីខ្លះ? សត្វស្រុកណាខ្លះដែលយើងស៊ីសាច់វាជាអាហារ? អ្នកចូលចិត្តសាច់ណា? ពីព្រោះអ្វី? (ល)

បង្រៀនពាក្យ - សុំធ្វើដូចមានរបៀបខាងលើស្រាប ដោយសួរឲ្យរកពាក្យដែលប្រសដូចគ្នាហើយឲ្យចេះរកពាក្យផ្ទុយផង ដូចពាក្យផ្ទុយនឹងពាក្យ ទន់ (រឹង) ផុយ (ស្វិត) ។ល។

នាម– សត្វស្រុក សាច់ជ្រូក គោ ពពែ ចៀម មាន់ ទា

គុណនាម– ទន់ ខ្ចី ផុយ រលួយ ស្អុយ ឆ្អាប

កិរិយាសព្ទ- ទិញសាច់គោ ហាន់សាច់ជ្រូក ស្រុះទា បោចមាន់

ហាត់សរសេរ-១- ចូររកពាក្យផ្ទុយនឹងពាក្យខ្ចី ស្វិត រឹង ។

២- បំពេញសេចក្ដីខាងក្រោមនៅកន្លែងចន្លោះ

សាច់....... មិនសូវមានខ្លាញ់ដូចសាច់ ........ទេខ្ញុំមិនហ៊ាន សម្លាប់ ...... យកសាច់លក់ទេព្រោះខ្លាច ...... ។

អាទិត្យទី ២- សត្វព្រៃដែលយើងយកសាច់ធ្វើជាអាហារ

ធាំស័ស្សនិយាយ - អ្នកដែលទៅលេងព្រៃឬទេ? អ្នកស្គាល់សត្វព្រៃណាខ្លះ? អ្នកដែលអាស្រ័យសាច់សត្វព្រៃណាខ្លះ សត្វព្រៃណាខ្លះដែលយើងបរិភោគសាច់វាជាអាហារ?

បង្រៀនពាក្យ- សុំធ្វើដូចអាទិត្យទី ១ មានរបៀបសព្វគ្រប់ហើយ ។

នាម- សត្វព្រៃ ប្រើស ក្ដាន់ ឈ្លុះ ជ្រូកព្រៃ ទន្សាយ ទន្សោង មាន់ទោរ ទុង រនាល ទោម ក្រសារ

គុណនាម- ធាត់ ស្គម តូច ធំ ឆ្ងាញ់

កិរិយាសព្ទ- បាញ់ក្ដាន់ ដេញជ្រូកព្រៃ បណ្ដាញទន្សោង ដាក់អន្ទាក់រនាល ។

ហាត់សរសេរ– ១– អន្ទាក់កើតមកពីពាក្យ ...... (ទាក់)

ចូរបំពេញសេចក្ដីខាងក្រោមនេះនឹងពាក្យដេញហើយនឹងពាក្យបណ្ដេញ

បងខ្ញុំគាត់បានបបួលគ្នាច្រើន .... ទន្សាយ មានមនុស្សខ្លះបួលចិត្តយកឆ្កែទៅ ....... សត្វ ៗ

## ២– ការដាំបាយ

នាំសិស្សនិយាយ– អ្នកចេះដាំបាយឬទេ? អ្នកណាដាំបាយឲ្យអ្នកអាស្រ័យ? អ្នកដែលឃើញម្ដាយអ្នកដាំបាយឬទេ? មុនដំបូងគាត់ធ្វើដូចម្ដេច? បង្កាត់ភ្លើងហើយធ្វើដូចម្ដេចទៀត? ដាំឆ្នាំងហើយគាត់ធ្វើយ៉ាងណាទៀត? លុះបាយពុះគាត់ធ្វើដូចម្ដេច?

បង្រៀនពាក្យ– សុំបង្រៀនពាក្យឆ្អិន បំអិន ឆ្ងន់ ទម្ងន់ ស្ងួត សម្ងួត

នាម– អុស ភ្លើង អង្ករ ទឹក ឆ្នាំង

គុណនាម ស្ងួត ស្រស់ ក្ដៅ ស ឆ្អិន ឆ្ងន់ ឆ្អែត

កិរិយាសព្ទ– បង្កាត់ភ្លើង លាងអង្ករ ដាំឆ្នាំង ដាក់បាយ

ហាត់សរសេរ – ១ – ចូររកពាក្យផ្ទុយនឹងពាក្យឆ្អិន ឆ្ងន់ ស្ងួត

២ – ចូរបំពេញសេចក្ដីខាងក្រោមនេះឲ្យបានត្រឹមត្រូវ

បង់ស្រ៊ូវដាក់ ...... ក្នុងបង្ក្រានហើយបង្កាត់ ...... ឲ្យឆេះរួចលាង ...... ប្រកក្នុងឆ្នាំងលើកដាំលើ ...... លុះបាយពុះគាត់ ...... ឲ្យស្រស់ទឹកដាក់ផ្ទុំតាល់តែ ...... បានដួសដោះយកមក ...... ។

អាធិត្យទី ៣ — ១_ អំពីបំណាំនឹងផ្លែឈើ

សុំនាំសិស្សនិយាយសួរសាកឲ្យបានសេចក្តីផង ដូចមានរបៀបខាងលើស្រាប់ ។

នាម– បង្អែម. នំ ស្ករ តាំងម៉ែ. ផ្លែឈើ ល្មុត អំពៅ ដូង ខ្នុរ ស្វាយ ចេក ធុរេន មង្ឃុត. សាវម៉ាវ

គុណនាម– ផ្អែម. ឆ្ងាញ់ ឈ្ងុយ. ទុំ ខ្ចី ស្រគៀល ជូរ ចត់

កិរិយាសព្ទ– ពិសាបំណី ទិញនំ លក់ស្ករ បេះស្វាយ សកអំពៅ បកចេក

សុំបង្រៀនពាក្យ– ផ្អែម បង្អែម ទិញ ទំនិញ រែក ដងរែក សង្រែក បក សំបក សក សំណក

ហាត់សរសេរ– ចូរបំពេញសេចក្តីខាងក្រោមនេះ ។

ចិននៅភូមិខ្ញុំលក់....(ទំនិញ) ថ្លៃណាស់ ។ គេរែកក្អមទឹង..(សង្រែក) ផ្តៅ ។ ប្អូនខ្ញុំ...(បក)ចេកស៊ី បងខ្ញុំយកថ្កទឹង...(ដងរែក) ឬស្សី ។

ពីល្ងាចមិញឪពុកខ្ញុំគាត់ទៅបេះផ្លែខ្នុរបានឃើញ..(សំណាក)ពស់មួយកន្ទុំ ស្ទើរចឹបតែនឹង...(សក) ។

## ២- ត្រូវប្រយ័ត្នបំណើអាហារវេលាដែលមានជម្ងឺឆ្លង

សុំនាំសិស្សនិយាយសួរទៅឆ្លើយឆ្លងដូចជាអ្នកស្គាល់ជម្ងឺណាខ្លះដែលឆ្លង ហើយស្លាប់មនុស្សជាច្រើន ។ ជម្ងឺនេះបណ្ដាលពីអ្វី ? អ្នកជម្ងឺនោះចាប់ឈឺឡើងយ៉ាងដូចម្ដេច ? ត្រូវធ្វើយ៉ាងដូចម្ដេចនឹងជៀសជម្ងឺនេះបាន ?(ល)

ពាក្យ- ជម្ងឺ មេរោគ អាសន្នរោគ ពិស បំណើ អាហារ បន្លែ ថ្នាំ គ្រូពេទ្យ

គុណនាម– ខ្លាំង រិត ស្ងួត ស្អោក ឆៅ ស្អុត រន្ធត់ ពុក

កិរិយាសព្ទ– កុំបរិភោគបំណើច្រើន កុំអាស្រ័យអាហារត្រជាក់ ត្រូវរត់ទៅរកគ្រូពេទ្យ ។

## អាទិត្យទី ៤.- ច្បារបន្លែ

១– វិធីហាត់ភាសា– នៅក្បែរផ្ទះខ្ញុំទីងយួនគេសំគាល់ឃើញមានអ្វី? ក្នុងច្បារនោះគេច្រើនដាំអ្វី? ដីរអ្វីខ្លះដែលអ្នកស្គាល់? បន្លែអ្វីខ្លះដែលអ្នកស្គាល់? ដើម្បីឲ្យដំណាំបានលូតលាស់ល្អគេត្រូវធ្វើដូចម្ដេច? បន្លែមានប្រយោជន៍ឬទេ? គេយកបន្លែទៅធ្វើអ្វីខ្លះ? បើគ្មានបន្លែបានឬទេ?

២– បង្រៀនពាក្យ– នាម. ច្បារបន្លែ ចំការបន្លែដីរ បន្លែស្ពៃ សាឡាត់ ខាត់ណា ត្រប់ ប៉េងប៉ោះ ខ្ញី រំដេង ត្រសក់ សណ្តែក ពពាយ ម្រះ ឃ្លោក ត្រឡាច រនោង រពៅ ខ្ទឹម ស្លឹកគ្រៃ ដំឡូង រដូវស្វា រដូវក្រាំង

គុណនាម: ស្រស់ ក្រៀម ស្វិត ស្រពោន ចាស់ ខ្ចី ល្វីង ហឹរ ក្តៅ ត្រជាក់ ទុំ រលួយ ឆ្ងាញ់ ខៀវ លឿង រញូម

កិរិយាសព្ទ: ដាំបន្លែ ចាររបង ជីកអណ្តូង បេះត្រប់ កាត់-បន្លែ ប្រមូលស្លឹកគ្រៃ ដកស្មៅ ជ្រួយដី ស្រោចស្រប់បន្លែ កាប់ដី ដំរះស្មៅ បង្ហូរទឹក ទៅផ្សារ លក់បន្លែ ។

## បង្រៀនមើលសូត្រ

## ច្បារបន្លែ

នៅមុខផ្ទះឬក្រោយផ្ទះខ្មែរនឹងយួន តែងមានច្បារបន្លែមួយដែរ នៅក្នុងច្បារនោះគេដាំដីរខ្ទឹមស្លឹកគ្រៃ ដែលជាគ្រឿងគេត្រូវការជារាល់ថ្ងៃព្រឹកល្ងាច បើនៅជុំវិញផ្ទះគ្មានសល់ដីទំនេរទេ ក៏គង់តែគេធៀតដាំក្នុងពាង ផើងឬឡាំងហើយដាក់នៅចុងកន្សាលឬនៅសន្ទាប់ផ្ទះជាពុំខាន ។

នៅក្រោយផ្ទះខ្ញុំមានចំការបន្លែមួយមានរបងព័ទ្ធជុំវិញ ហើយមាន

អណ្តូងនៅជិត ក្នុងចំការនោះខ្ញុំកាប់ដីលើកថ្នាលហើយដាំបន្លែទឹងដែរ គ្រប់មុខ មានជីរអង្កាម ជីរនាងវង់ ក្រសាំងទំហំ ស្លឹកគ្រៃ ខ្ទឹម វ៉ាន់ស៊ុយ ម្ទេះ ពួកបន្លែមាន ស្ពៃ សាឡាត់ ខាត់ណា ត្រប់ប៉េងប៉ស់ ខ្ញីរំដេង ត្រសក់ សណ្តែក ពពាយ ម្រះ រនោង ឃ្លោកត្រឡាច បន្លែទាំងនេះ ជាអាហារល្អណាស់ មានមនុស្សមករកទិញដល់ផ្ទះជារាល់ថ្ងៃព្រឹកល្ងាច ប៉ុន្តែជួនកាលម្តាយខ្ញុំបេះបន្លែនេះទៅលក់ឯផ្សារ បន្លែដែលស្រស់ល្អលក់ ដាច់ដាច់ណាស់ ដាំបន្លែបានតែនៅទីដីណាមានដីជាតិល្អមានមេទឹកជិត ពីព្រោះបន្លែនឹងលូតលាស់ល្អបានលុះតែគេស្រោចទឹករាល់ថ្ងៃ បើគ្មានទឹក បរិបូណ៌ទេ បន្លែក៏ពុំអាចនឹងបានល្អឡើយ ហេតុដូច្នេះបានជាបន្លែនេះ រស់ល្អតែក្នុងរដូវវស្សា ពីព្រោះមានទឹកភ្លៀង កាលណាដល់រដូវប្រាំង អ្នករកស៊ីដាំបន្លែលក់នឿយណាស់ នឹងរែកទឹកស្រោចស្រប់បន្លែ ។

---

កុមារដ្ឋាន

## រៀនពាក្យនិងភាសា

អាទិត្យទី ១.— ខ្លួនមនុស្ស

ពាក្យ. ខ្លួន, ក្បាល, អវយវៈ គឺ ដៃ, ជើង, ក, មុខ, លលាដ៍.

ក្បាល, មាត់, ច្រមុះ, ភ្នែក, ថ្ងាស, ត្រចៀក, ថ្ពាល់, កំភ្លៀង, ចង្កា, រន្ធច្រមុះ, រន្ធត្រចៀក, ថ្គាម ។ ស្មា, ដើមទ្រូង, ពោះ, ខ្នង, ចង្កេះ ស្លាបប្រចៀវ. ក្លៀក ។

ភាសា ឲ្យយកក្មេងម្នាក់មកឈរមុខក្មេងទាំងឡាយក្នុងថ្នាក់ រូបត្រូវបង្អុលប្រាប់មើលរូបក្មេងនោះ ពាក្យរបស់សារីរៈពងកាយដែលត្រូវបង្រៀន ឯណាខ្លួនរបស់អ្នក? (នេះខ្លួនរបស់ខ្ញុំបាទ) ។ ខ្លួនរបស់អ្នកខាងលើហៅអ្វី? (ក្បាល) ។ ចុះក្រោមក្បាលហៅអ្វី? (ក) ។ ចុះក្រោមកមក? (ដងខ្លួន) ។ ចំណែកខ្លួនត្រង់ណាខ្លះដែលហៅថាអវយវៈ ។ (ដៃជើង) (សុំឲ្យធ្វើពាក្យសួរតាមលំនាំដែលយើងឲ្យដូច្នេះតទៅ) ។

## ខ្លួនមនុស្ស (ត)

ពាក្យ ដៃ, ដើមដៃ, កំភួនដៃ, កដៃ, ខ្នងដៃ; បាតដៃ, ម្រាមដៃ, កែងដៃ, មេដៃ, ចង្អុលដៃ, ចង្អុលខ្មោចឬម្រាមកណ្ដាល, នាងដៃ, កូនដៃ ។ ជើង, ភ្លៅ, កំភួនជើង, ជើង ។ ជង្គង់, គន្ទាក់ពាចម៌, ស្មង, កជើង, បាតជើង, ខ្នងជើង, ភ្នែកគោ, ម្រាមជើង មេជើង, កូនជើង, ម្រាមកណ្ដាល, ត្រគៀក, កណ្ដៀតគុម, គូថ,

( ទីខាងក្រោមតាំងមូល ) បាលីទ្វារលាមក ។ កញ្ចឹងក, សៀតផ្កា សក់, រោមប្លោម, ចិញ្ចើម, រោមភ្នែក, ពុកចង្កា, ពុកមាត់, ក្រចក ។

អាទិត្យទី ៣— ខ្លួនមនុស្ស (ត)

ពាក្យ សាច់, ស្បែក, ឆ្អឹង, សរសៃ, ឈាម, ទឹកមាត់, ទឹកភ្នែក, ខ្ទុះ, ទឹកមូត្រ, ខ្យល់ដង្ហើម, ជីពចរ ។ ដើប, ដក់, អើត, ដេក, ដើរ, ឈរ, អង្គុយ, រត់, ស្ទាប, អង្អែល, ចាប់, ពាល់, កាន់, លើក, ដាក់, មើល, សម្លឹង, ស្ដាប់, ហិត, ស៊ី, ផឹក, ស្រូប, និយាយ, យំ, ស្រែក, ទំពា, ជាន់, ជិះ, ផ្អែកទ្រាល, លោត, ស្ទាប, ប្រត់, រុញ-ដោល

អាទិត្យទី ៤- ខ្លួនមនុស្ស (ត)

ពាក្យ— សុំឲ្យរកគុណនាមមកបំពេញបទនឹងនាមដែលរៀនរួចហើយពីអាទិត្យមុន ៗ ក្បាលមូល, ខ្លួនធំ, ដៃវែង, កខ្លី, ស្បែកស្ដើង សាច់ទន់, សរសៃយឺត; ឈាមក្រហម, ទឹកមាត់ការ

ភាសា— ក្បាលមនុស្សមានទ្រង់ទ្រាយដូចម្ដេច ? ក្នុងខ្លួនយើង តាំងមូលអ្វីខ្លះដែលមានសណ្ឋានរឹង ? សណ្ឋានទន់ ?

រៀនមើលសរសេរ

អាទិត្យទី ១– មេរៀនទី៦ (វិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ១៤)

ក្នុងអាទិត្យទី ១ – នេះត្រូវបង្រៀនឲ្យចេះអក្សរ ១ មួយថ្ងៃ តាំងពីតួរអក្សរ តាំងអក្សរផ្សំស្រៈ ( បំបែក ) ឯអក្សរព្យញ្ជនៈដែលរៀនហើយក៏ត្រូវសរសេរទុកនៅក្ដារខៀនដរាប ដើម្បីឲ្យក្មេងឃើញជានិច្ច ។ នឹងបង្រៀនអក្សរមួយ ៗ ត្រូវរកពាក្យបណ្ដុះស្មារតីផងដូចបង្រៀនអក្សរ ឆ ឲ្យថា ឆ ឆក់· ឆបោក. ស្ងួរឆ.... ។ កាលបើក្មេងចេះស្គាល់តាំងសរសេរតួអក្សរតាំងវិស័តួអក្សរតាំងបំបែកទើបផ្ដុំព្យញ្ជនៈបំបែកក្ដី តួព្យញ្ជនៈតួទទេក្ដី ជាពាក្យពីរបីម៉ាត់ឲ្យមើល ឲ្យសរសេរចុះក្នុងសៀវភៅ ។

អាទិត្យទី ២ – មេរៀនទី ៧ (ខេមរភាសាទំព័រ ១៤)

ការចំណាំ សុំឲ្យបង្រៀនអក្សរ ឬ កន្ទង់ ឬ អក្សរជើងតម្រួតទីងដើមប

អាទិត្យទី ៣ – មេរៀនទី ៨ (វិជ្ជាខេមរភាសាទំព័រ ១៦)

អាទិត្យទី ៤ – មេរៀនទី ៩ (សៀវភៅដដែលទំព័រ ១៩-២១)

## តែងសេចក្ដី

សម្រាប់ប្រឋមភូមិបំពេញវិជ្ជា

កម្មវិធីសម្រាប់ខែ – ការពប់រៀបអំពីចលនា – ពិព័ណនាអំពីចលនា ។

## ១- ការរាប់រៀបអំពីចលនា

សេចក្តីព្រាង — ក្នុងការតែងសេចក្តីបំពូកនេះ គេអាចក្រងសេចក្តីតាមគោលខាងក្រោមនេះ ៖

១- ពេលមុនចលនាកើត ៖ កាលៈទេសៈ កិច្ចប្រុងប្រៀប ។

២- តួចលនា ៖ ហេតុផ្សេងៗដែលកើតឡើងជាលំដាប់បន្តបន្ទាប់គ្នា ។

៣- ពេលក្រោយចលនាកើត ៖ លទ្ធផលដែលបណ្តាលឡើងការហាប់អារម្មណ៍ដែលចលនានោះបង្កើតឲ្យមានដល់រូបយើង ។

រឿងតែង — ចូរអ្នករាប់រៀបអស់ទាំងអំពើដែលអ្នកបានបំពេញពីព្រឹកមិញ មុនអ្នកចេញមកកាន់សាលារៀន ។

ការរៀបចំ - រាល់ព្រឹកអ្នកណាដាស់អ្នក ? អ្នកភ្ញាក់ពីដំណេកនៅពេលម៉ោងប៉ុន្មាន ? អ្នកធ្វើអ្វីនៅពេលបន្ទាប់ពីអ្នកភ្ញាក់ឡើងភ្លាម ? អ្នកធ្វើអ្វីខ្លះជាកិច្ចសំអាតខ្លួន ? អ្នកបានមើលមេរៀនបញ្ជាក់ជាថ្មីឬទេ ? ប្រយោជន៍អ្វី ? បន្ទាប់មកអ្នកធ្វើអ្វី ? អ្នកអាស្រ័យអ្វីជាកិច្ចស្រស់ស្រូប ? អ្នករៀបចំអ្វីនៅពេលក្រោយបង្អស់ ? អ្នកចេញមកសាលារៀននៅពេលម៉ោងប៉ុន្មាន ? មាតាបិតាអ្នកមានរំឭកអ្វីដល់អ្នកឬទេ ? អ្នកឆ្លើយដំរាបគាត់ដូចម្តេច ?

## គោលសេចក្ដី

១– ពេលអ្នកភ្ញាក់ពីនិទ្រា ។

២– អ្នករៀបចំដំណេកបន្ទប់នឹងកិច្ចផ្សេងៗទៀត(ដងទឹកបោសកូម

៣– អ្នកលុបលាងមុខ–មាត់នឹងសំអាតរាងកាយ ។

៤– អ្នកមើលមេរៀនបញ្ជាក់ឡើងវិញ ។

៥– អ្នកស្រស់ស្រូប ។

៦– អ្នករៀបចំខ្លួននឹងឧបករណ៍ ។ អ្នកចេញទៅរៀន ។

៧– ពាក្យរំឭករបស់មាតាបិតាអ្នក ពាក្យសន្យារបស់អ្នក ។

### ២– ពិព័ណ៌នាអំពីចលនា

រឿងតែង– ចូរអ្នកធ្វើពិព័ណ៌នាអំពីភ្លើងឆេះផ្ទះដែលអ្នកបានឃើញ ។

## គោលសេចក្ដី

១– គ្រប់ខ័ណ្ឌរបស់ចលនា៖ ពេលនឹងទីកន្លែង ។

២– ដំណើរផ្សេងៗរបស់អគ្គិ ។

៣– កិច្ចជំនួយដើម្បីរំងាប់ភ្លើង ។

៤– ការចាប់អារម្មណ៍ ។

## សេចក្ដីអធិប្បាយ

កាលពីល្ងាចថ្ងៃសៅរ៍មុននេះ ប្រហែលជាម៉ោង ៩ ល្ងាចនៅពេលដែលខ្ញុំបាទកំពុងទន្ទេញមេរៀន ស្រាប់តែខ្ញុំបាទឮសូរអ្នកស្រុកស្រែកលាន់ពេញថាភ្លើងឆេះផ្ទះ! ភ្លើងឆេះផ្ទះ! ឯសូរនៅទីវត្តក៏បន្លឺសព្ទយ៉ាងញាប់ខ្ទាន់លាយនឹងសំរែកមនុស្ស ៗ ខ្ញុំបាទក៏ស្ទុះចេញទៅក្រៅភ្លាមហើយក្រឡេកមើលទៅទិសខាងកើតឃើញអណ្ដាតភ្លើងលេចឡើងខ្ពស់ផុតចុងត្នោតទាំងឡាយ ៗ ខ្ញុំបាទក៏លើកទោចក្រយានដាក់មកដីហើយជិះយ៉ាងលឿនសំដៅទៅកាន់ទីមានភ័យនោះ ៗ

លុះទៅដល់ជិតបុរីភូមិ ខ្ញុំបាទឃើញផ្ទះឈើប្រក់ក្បឿងមួយដែលជារបស់ចៅកែចិកកំពុងត្រូវភ្លើងឆេះសន្ធោសន្ធៅ ដោយមានអណ្ដាតភ្លើងចេញភ្លែតៗពីគ្រប់បន្ទប់ទាំងអស់ មានផ្សែងយ៉ាងក្រាស់ហុយកួលខ្មាញ់ចេញពីដំបូលៗ មួយស្របក់បន្ទាប់មកស្រាប់តែឮសន្ធឹកលាន់យ៉ាងខ្លាំងព្រមទាំងមានកំសួលផ្សែងយ៉ាងធំស្ទុះឡើងទៅលើមេឃ គឺជាហេតុបណ្ដាលមកពីផ្ទាំងដំបូលមួយចំហៀង ឆេះព្រាមធ្លាក់មកក្រោម ៗ អណ្ដាតភ្លើងលេចចេញឡើងកាន់តែខ្លាំងឡើង ៗ បណ្ដាលឲ្យអ្នកជិតខាងតក់ស្លុតជាពន្លឹក ខ្លាចក្រែងឆេះផ្ទះខ្លួនទៀត ៗ ឯផ្កាភ្លើងក៏ស្ទុះចេញមកជាច្រើនអណ្ដែតពេញអាកាសដោយត្រូវខ្យល់បក់មកបន្តិចៗផង ៗ

អ្នកស្រុកមានចំនួនប្រហែលបីបួនរយនាក់ផ្អើលមកកាន់ទីនោះឈរមើលភ្លើង ដោយស្ងប់ស្ងាត់ ។ ដោយផុតសង្ឃឹមនឹងរំលត់ភ្លើងបាន គេខំប្រឹងការពារកុំឲ្យតែរាលដាលទៅទៀត ។ មានជនអ្នកស្រុកចិត្តប្រហែលហាសិបឬហុកសិបនាក់ពួតដៃគ្នាជាពួកជាក្រុមដើម្បីជួយបង្អាក់ភ្លើងកុំឲ្យឆាបឆេះផ្ទះជិតៗដោយមានមេឃុំនឹងជំទប់ជាអ្នកបញ្ជាការ ។ អ្នកខ្លះឡើងលើដំបូលផ្ទះយកទឹកទៅស្រោចផ្សើមដំបូល អ្នកខ្លះដាក់ជញ្ជាំងទម្លាក់មកដី ខ្លះទៀតឈរបន្តគ្នាជាជួរ ហើយហុចប៉ោតទឹកពីមួយទៅមួយឲ្យទៅអ្នកនៅលើដំបូលផ្ទះ ។

ភ្លើងពុំអាចឆ្លងទៅឆេះផ្ទះនៅជុំវិញបានដោយសារកិច្ចជំនួយនេះ ។ រីឯផ្ទះថៅកែចិកដែលមានទំហំដល់ទៅ ១៥ ម៉ែត្របណ្ដោយ ត្រូវភ្លើងបំផ្លាញក្លាយទៅជាគំនរកំទេចឈើមួយពុំទុកឆេះហុយទ្រលោម ។ ពួកគ្រួសារ ថៅកែចិកយំឡោកខ្លួនដោយសេចក្ដីសោកស្ដាយទ្រព្យសម្បត្តិដែលខ្លួនខំសន្សំទុកជាយូរឆ្នាំណាស់មកហើយ ហើយត្រូវវិនាសតែមួយភ្លែតបែបនេះ ។

ខ្ញុំបានចាកចេញពីទីនោះមកនៅពេលម៉ោង ១២ អាធ្រាត្រ ក្នុងចិត្តពោរពេញដោយសេចក្ដីអាណិតដល់គ្រួសារអ្នកបាបគ្រោះនេះពន់ពេក ។

អធិស្ឋាន

## តែងសេក្ដី

## អំពីម្រឹគ

រកគំនូរដែលមានសត្វព្រៃគ្រប់យ៉ាងមកឲ្យសិស្សមើល ហើយសួរសិស្សណែនាំឲ្យឆ្លើយមាត់ទទេសិន ។

នៅស្រុកអ្នកមានសត្វព្រៃឬទេ? អ្នកស្គាល់សត្វព្រៃអ្វីខ្លះ? សត្វណាដែលធំជាងគេ ? សត្វណាដែលតូចជាងគេ ? សត្វខ្លាស៊ីអ្វីជាអាហារ ? សត្វដំរីស៊ីសាច់ជាអាហារឬទេ ? សត្វប្រើសរមាំងក្តាន់វាស៊ីអ្វី ? សត្វស្វាទោចវាស៊ីអ្វី ? (ល)

### តែងសេចក្ដីទី១

ចូរតែងសេចក្ដីអធិប្បាយអំពីសត្វព្រៃមានសត្វអ្វីខ្លះ ? សត្វព្រៃដូចគ្នាទាំងអស់ឬទេ ? សត្វណាខ្លះដែលស៊ីស្មៅជាអាហារ ? សត្វណាខ្លះដែលស៊ីសាច់ជាអាហារ ? សត្វណាខ្លះដែលស៊ីផ្លែឈើជាអាហារ ? បើទៅក្នុងព្រៃគេខ្លាចសត្វអ្វីខ្លះ ? ពីព្រោះអ្វីបានជាគេខ្លាចសត្វខ្លា ខ្លាចសត្វដំរី ខ្លាចសត្វពស់ ?

## គំរូតែងសេចក្ដី

សត្វព្រៃមានច្រើនយ៉ាងណាស់គឺៈ ខ្លា, ដំរី, រមាស, រមាំង, ក្ដាន់, ប្រើសទ្រាយ, ទន្សោង, ទន្សាយ, ឈ្លូស, ខ្ទីង, ជ្រូកព្រៃ, ក្របីព្រៃ, គោព្រៃ, ស្វាន. ស្វា, ទោច, បបក, សំពោច, (ល)

សត្វព្រៃពុំដូចគ្នាទាំងអស់ទេ ខ្លះតូច ខ្លះធំ ខ្លះកាច ខ្លះស្លូត ខ្លះស៊ីស្មៅ ខ្លះស៊ីសាច់ ខ្លះស៊ីផ្លែឈើមើមឈើជាអាហារ។ សត្វដែលស៊ីស្មៅជាអាហារគឺៈ ប្រើស. ទ្រាយ. រមាំង. ក្ដាន់. ទន្សោង. ទន្សាយ. ក្របីព្រៃ. គោព្រៃ. ខ្ទីង. ដំរី. (ល)

សត្វដែលស៊ីសាច់ជាអាហារគឺៈ ខ្លាធំ, ខ្លាដំបង, ខ្លារខិន, ខ្លាត្រី, កញ្ជ្រោង, ស្កា, បបក, ឆ្កែព្រៃ, សំពោច, (ល)

សត្វដែលស៊ីផ្លែឈើជាអាហារគឺៈ ស្វា, ទោច, កំប្រុក, កង្ហួន (ល)

បើចូលទៅក្នុងព្រៃគេខ្លាចសត្វខ្លា សត្វដំរី, សត្វពស់, ពីព្រោះខ្លាវាខាំ ដំរីវាព្រួច ពស់វាចឹក

## សេចក្ដីតែងទី ២

ចូរអ្នកអធិប្បាយអំពីព្រានព្រៃម្នាក់ដែលអ្នកស្គាល់តាមពាក្យចោទខាងក្រោមនេះ

នៅភូមិអ្នកមានព្រានព្រៃម្នាក់ឬទេ ? ព្រាននោះឈ្មោះអ្វី ? គាត់បាញ់សត្វនឹងអ្វី ? កាលណាឃើញសត្វព្រាននោះធ្វើដូចម្ដេច ? ព្រានបាញ់សត្វប្រយោជន៍អ្វី ? អ្នកចូលចិត្តនឹងព្រាននោះឬទេ ពីព្រោះអ្វី ?

## សេចក្ដីតែងទី ៣

ចូរអ្នកអធិប្បាយអំពីអ្នកបានទៅស្ទូចត្រីតាមពាក្យចោទខាងក្រោមនេះ

អ្នកដែលបានទៅស្ទូចត្រីឬទេ ? អ្នកទៅស្ទូចត្រីនៅពេលណា ? អ្នកស្ទូចត្រីនឹងអ្វី ? អ្នកធ្វើដូចម្ដេចមុននឹងស្ទូច ? លុះបិតនុយនៅផ្លែសន្ទូចរួចហើយអ្នកធ្វើដូចម្ដេចទៀត ? ហេតុអ្វីបានជាអ្នកដឹងថាត្រីស៊ីនុយ ? កាលណាដឹងថាត្រីស៊ីនុយហើយអ្នកធ្វើដូចម្ដេច ? អ្នកត្រេកអរនឹងស្ទូចបានត្រីឬទេ ? ពីព្រោះអ្វី ?

---

## បរិច្ចណដ្ឋាន

---

### តែងសេចក្ដី

# សរុបរឿង អំពីអាហារ

សំនាំ - ដូចបានពណ៌នាមកហើយថានៅខែដំបូងត្រូវបង្រៀន

សិស្សនូវវិធីឲ្យឆ្លើយដោយមាត់ទទេសិន រួចទើបដាក់ការហាត់សរសេរឲ្យធ្វើ ។

## សេចក្ដីតែងទី ១

## អំពីអាហារ

វិធីហាត់មាត់ទទេ.– យើងត្រូវបរិភោគអ្វីឲ្យរស់ជីវិត? មុននឹងបរិភោគគេយកអាហារទៅធ្វើដូចម្ដេច? គេដាក់អាហារនឹងអ្វីយកមកបរិភោគ? អ្នកត្រូវបរិភោគអាហារឆៅឬទេ? ពីព្រោះអ្វី?

### វិធីហាត់សរសេរ

ចូររើសរកពាក្យត្រឹមត្រូវមកដាក់បំពេញបន្លោះឃ្លាខាងក្រោមនេះ ។

រាល់ថ្ងៃយើងបរិភោគ ...... ឲ្យរស់ជីវិត

អាហារទាំងឡាយត្រូវតែ.......ឲ្យឆ្អិនល្អមុននឹងយកមកអាស្រ័យ ។

គេដាក់អាហារក្នុង ........... ខ្ញុំមិនត្រូវទទួលទានអាហារ ......... ទេ ពីព្រោះអាហារមិនឆ្អិនតែងបណ្ដាលឲ្យ......... ។

## សេចក្តីតែងទី ២

# ពេលបរិភោគអាហារ

វិធីហាត់មាត់ទទេ — អ្នកបរិភោគអាហារប៉ុន្មានពេលក្នុងមួយថ្ងៃ ?

អ្នកណាធ្វើអាហារឱ្យអ្នកបរិភោគ ?

អ្នកអង្គុយបរិភោគនៅលើអ្វី ?

អ្នកចាប់អាហារបរិភោគនឹងអ្វី ?

អ្នកហុតទឹកសម្លនឹងអ្វី ?

ពីព្រោះអ្វីបានជាអ្នកពុំចាប់អាហារនឹងដៃ ?

វិធីហាត់សរសេរ— សូមគ្រូរៀបចំរឿងតែងនេះ ។

## សេចក្តីតែងទី ៣

# អំពីសួនច្បារ

ឯវិធីបង្ហាត់សិស្សឱ្យចេះតែងសេចក្តីនេះយើងពុំចាំបាច់តែងរបៀបជូនគ្រូទេ ព្រោះយើងបានធ្វើពីអាទិត្យមុនជូនទុកជាគំរូស្រាប់ហើយ ដូច្នេះសុំគ្រូមើលហើយធ្វើតាមរបៀបនោះចុះ ។

អាធិកាដ្ឋា

## នព្វន្ត

## ចំនួនពី ១០០ ដល់ ១.០០០

### ថ្លៃដើម ថ្លៃលក់ ប្រាក់ចំណេញ

អាទិត្យទី ១ បង្រៀនចំនួនពី ១០០ ដល់ ៥០០

ដូចបាននិយាយអំពីខែមុនស្រាប់ បើនឹងបង្រៀនចំនួនណិមួយៗ ត្រូវបញ្ជាក់ចំនួននោះ គឺត្រូវប្រើចង្កើះ ។

ដើម្បីនឹងបញ្ជាក់ពីខ្ទង់ទៀត សូមគ្រូរកប្រអប់ ៣ ហើយសរសេរដាក់នៅខាងមុខប្រអប់នោះថា ខ្ទង់រយ ខ្ទង់ដប់ ខ្ទង់រាយ ឧបមាដូចជា ១៤២ ត្រូវយកចង្កើះ ១ ដាក់ក្នុងប្រអប់ខ្ទង់រយ មើលថាមួយរយ យកចង្កើះ ៤ ដាក់ក្នុងប្រអប់ខ្ទង់ដប់ គឺដប់បួនដងត្រូវជាសែសិប ហើយនឹងចង្កើះរាយ ២ ដាក់ក្នុងប្រអប់ខ្ទង់រាយ ហើយប្រាប់សិស្សថា ទាំងអស់នេះចំនួនមួយរយសែសិបពីរ (១៤២) ។

សូមឲ្យសិស្សរើសចង្កើះដាក់ក្នុងប្រអប់តាមចំនួនដែលគ្រូបង្គាប់ ។ រួចគ្រូសរសេរចំនួនដែលសិស្សរកឃើញនៅលើក្តារខៀន ។

ហាត់មើលចំនួន - ឲ្យសិស្សមើលចំនួនដែលគ្រូបានសរសេរ

នៅលើក្តារខៀន ដូចជា: ១១១, ១៤៦, ២៣៧, ២៤២, ៣២១, ៣៤៩, ៤៥៦, ៥០០, ៤៧១, ៣៦២, (ល)

ហាត់រាប់ចំនួន ឲ្យរាប់ថែមពីរ ៗ បី ៗ បួន ៗ ប្រាំ ៗ ពី ១០០ ដល់ ៥០០ រួចរាប់សាចុះមកវិញ ។

ហាត់សរសេរចំនួនលើក្តារឆ្នួន- ឲ្យសិស្សសរសេរលេខតាមគ្រូថា: ៤៥១, ១០៣, ២៦៧, ៣៤១, ២៥៨, ៥០០; ៤៩២, ៣៣៦ ។ល។

ហាត់គិតមាត់ទទេ- ត្រឡាប ២៧៦ លក់អស់ត្រឡាប ៣៦ នៅសល់ត្រឡាប........ ។

ឈ្មួញម្នាក់ជួលកិនពោតម្តងបាន ២៨៧ បាវ ម្តងទៀត ១២១ បាវ តើឈ្មួញនោះជួលគេកិនបានពោតប៉ុន្មានបាវទាំងអស់ ? ។

អាទិត្យទី ២- ចំនួនពី ៥០១ ដល់ ១.០០០

សូមបង្រៀនដូចអាទិត្យទី ១

លេខបូកមានត្រាទុក - ឪពុកខ្ញុំគាត់ទិញដែកគោល ១ កញ្ចប់ថ្លៃ ១៨៨រៀល លួសស្ពាន់ ១ បន្ទាយ ថ្លៃ ២៩៦រៀល ។ គាត់ប្រាប់ខ្ញុំថាឲ្យគិតរកចំនួនប្រាក់ដែលគាត់ចាយទាំងអស់ ។

ដើម្បីនឹងរកប្រាក់ដែលលោកឪពុកខ្ញុំចាយ ត្រូវបូកប្រាក់ថ្លៃដែកគោល

១៨៨៛ នឹង ២៩៦៛ ថ្លៃលួសស្ពាន់ ។

ឯរបៀបលេខបូកត្រាទុក ក៏ដូចជាលេខបូកឥតត្រាទុកដែរ គឺសរសេរចំនួនមួយក្រោមចំនួនមួយហើយគូសបន្ទាត់មួយនៅខាងក្រោម

| | |
|---|---|
| + ១៨៨៛ | រួចថា៖ ៨ នឹង ៦ ត្រូវជា ១៤ |
| ២៩៦៛ | ខ្ញុំសរសេរលេខ ៤ នៅក្រោម |
| ៤៨៤៛ | ខ្ទង់រាយ ខ្ញុំត្រាទុក ១ ។ |

១ ដែលត្រាទុកនឹង ៨ ត្រូវជា ៩ ។ ៩ នឹង ៩ ត្រូវជា ១៨ ខ្ញុំសរសេរលេខ ៨ នៅក្រោមខ្ទង់ដប់ ខ្ញុំត្រាទុក ១ ។ ១ ដែលត្រាទុកនឹង ១ ត្រូវជា ២ ។ ២ នឹង ២ ត្រូវជា ៤ ខ្ញុំសរសេរលេខ ៤ នៅក្រោមខ្ទង់រយ ទាំងអស់ខ្ញុំឃើញ ៤៨៤៛ ។ ដូច្នេះលោកឪពុកខ្ញុំចាយអស់ប្រាក់ចំនួន ៤៨៤៛ ។

ការហាត់ – ចូរធ្វើលេខខាងក្រោមនេះ

១៦៨ + ២៩៣ = ។ ៩៦ + ៣៧២ ។

៣១៦ + ១៧៤ = ។ ១០២ + ៣២៥ ។

ចំណោទ – ជាងឈើម្នាក់លក់ការៀមួយថ្លៃ ៦៦៩៛ គ្រែមួយថ្លៃ ៩២៦៛ ។ តើជាងឈើនោះលក់របស់ទាំងពីរមុខបានប្រាក់ប៉ុន្មាន ?

លេខសន្យានត្រាទុក ឧបមា៖ តុមួយនឹងទូមួយទិញមកថ្លៃ ៩២៣៛ ។ ឯតុថ្លៃ ៣៧៩៛ តើទូថ្លៃប៉ុន្មាន ទើបរកថ្លៃទូ ត្រូវយកថ្លៃ

គុៈ ៣៧៩៛ ដកចេញពីថ្លៃទូទាំង ២ មុខនោះ ។ ដូច្នេះត្រូវធ្វើលេខសង គឺខំសរសេរចំនួនតូចក្រោមចំនួនធំ ខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់ ខ្ទង់រយក្រោមខ្ទង់រយ រួចគេគូសបន្ទាត់មួយពីក្រោមចំនួនតូចនោះ,

| | |
|---|---|
| – ២៣៛ | គេយកលេខពីក្រោមទៅសងលេខខាង |
| ៣៧៩៛ | លើតាមខ្ទង់តាំងពី ខាងស្តាំទៅ រួចគេសរ |
| ៥៤៤៛ | សេរលេខសេសនៅខាងក្រោមខ្ទង់តាមជួរ ។ |

ការបាត់ – ចូរធ្វើលេខសងខាងក្រោមនេះ :

៤៧៩៛ - ៣៥៨៛ = ។ ៩៦៨៛ – ៧៨៩៛ =

៥៣១៛ ២៩៤៛ = ។ ៨៧២៛ - ៥៣៨៛ =

ចំណោទ.– អ្នកដាំម្រេចម្នាក់ បេះបានម្រេច ៨៦២ បាវ លក់អស់ម្តង ២០៤ បាវ ម្តងទៀត ៣៨៦ បាវ ។ តើឈ្មួញនោះ នៅសល់ម្រេចប៉ុន្មានបាវទៀត ។

អាទិត្យទី ៣.– អំពីថ្លៃដើម-ថ្លៃលក់-ប្រាក់ចំណេញ :

ថ្លៃដើមមាន២ យ៉ាង មួយយ៉ាងគឺថ្លៃដើមប្រាក់ដែលទិញមកឥតមានសោហ៊ុយ ឬប្រាក់បន្ថែមបន្ទាប់បន្សំទៀត ឧបមាដូចជាប៉ាន់តែមួយថ្លៃ ៤០៛ ។ មួយយ៉ាងទៀត ហៅថាថ្លៃដើម គិតរួមទាំងអស់ គឺជាថ្លៃដើមប្រាកដ ថែមថ្លៃឈ្នួលដឹកនាំឬថ្លៃពន្ធគយ ឬដម្លៃរបស់ដែលខូច

—

ខាតទៅហើយ ត្រូវថែមថ្លៃមកលើរបស់ដែលនៅសល់ ហើយទឹកសោហ៊ុយ ដែលផាច់ខាតទាំងអស់ផង ៗ ឧបមាដូចជាឈ្មួញម្នាក់ទិញនាឡិកាចងដៃពីស្រុកស្វីសមកលក់នៅស្រុកខ្មែរ ថ្លៃនាឡិកានោះ ៦៥០៛ នាំចូលមកស្រុកខ្មែរត្រូវបង់ពន្ធគយមួយ ២១០៛ ទៀត ថ្លៃសោហ៊ុយដឹកនាំ ៨៩រ ដូច្នេះដល់មកស្រុកខ្មែរ នាឡិកាចងដៃមួយ ថ្លៃដើមត្រូវ ៦៥០៛ + ២១០៛ + ៨៩ = ៩៤៩៛ ។

បើបង្រួមមកគឺថា : ថ្លៃដើម = ថ្លៃទិញ + សោហ៊ុយគ្រប់មុខ ។

ថ្លៃលក់ .– ឧបមាបើគេលក់នាឡិកាចងដៃនោះទៅវិញ ថ្លៃ ១០០០៛ ។ ក្នុង ១០០០៛ នេះ ឈ្មួញបានចំណេញបន្តិចបន្តួចពុំខាន ពីគេគិតយកចំណេញស្រេចទើបគេលក់ ។

បើចង់រកថ្លៃលក់ គេគិតដូចនេះ :

ថ្លៃដើម ប្រាក់ចំណេញ ថ្លៃលក់ ថ្លៃដើម + ចំណេញ

ថ្លៃលក់ ឬ ៩៤៩៛ + ៥១៛ = ១០០០៛ ឯ ៥១៛

ប្រាក់ចំណេញ បានមកពីផ្លូវលេខ: ១០០០៛ − ៩៤៩៛ = ៥១៛

ហាត់គិតមាត់ទទេ.– ថ្លៃដើមមានប៉ុន្មានបែប ?

ដូចម្តេចហៅថាថ្លៃលក់ ? ប្រាក់ចំណេញ ?

លំហាត់.– ១), ជាងឈើម្នាក់ទិញតុះបេង ១ ថ្លៃ៧៥១៛ លក់

គុះនោះទៅវិញថ្លៃ៩២៩៛ ។ តើជាងនោះបានចំណេញប៉ុន្មាន ?

២) ឈ្មួញម្នាក់លក់ស្ករ១០ ពាន់ ថ្លៃ៥៣០៛ ហើយគាត់បានចំណេញ ៩០៛ ។ តើស្ករ១០ពាន់នោះទិញមកថ្លៃប៉ុន្មាន ? ។

៣) ស្ត្រីម្នាក់ទិញត្រីស្រស់១ទូកតូចថ្លៃ៣២៧៛ ។ ដល់លក់ត្រីនោះអស់ទៅបានចំណេញ១២៥៛ ។ តើថ្លៃលក់ត្រីទាំងអស់ប៉ុន្មាន ?

## រង្វាស់រង្វាល់

សព្វថ្ងៃនេះ ខ្មែរច្រើនប្រើម៉ែត្រវាស់បណ្ដោយទទឹង កំពស់ វត្ថុទាំងឡាយ ប៉ុន្តែនៅស្រុកស្រែគេនៅប្រើខ្នាតពីដើមនៅឡើយ គឺហត្ថខ្នាតហ្លួង ។

ហត្ថខ្នាតហ្លួង ប្រវែងប្រហែល ០ម៥០ ដូច្នេះក្នុង១ម៉ែត្រមាន២ហត្ថ

រង្វាស់ ធំជាង ហត្ថខ្នាតហ្លួងគឺ:

១) ព្យាម មាន ៤ ហត្ថ ប្រហែល២ម៉ែត្រ ។

២) សិន មាន២០ព្យាម ប្រហែល ៤០ ម៉ែត្រ ។

៣) យោជន៍មាន៤០០សិន " ១៦ គីឡូម៉ែត្រ ។

រង្វាស់តូចជាងហត្ថខ្នាតហ្លួងគឺ:

១) ចំអាម គឺ ពាក់កណ្ដាលហត្ថ ឬ ០ម២៥ ។

២) ធ្នាប់ គឺ ១២ ភាគ តូចជាងចំអាមត្រូវជា ០ម០២ ។

## តារាងតំរៀបជំរូវខ្នាត

| | | | | | |
|---|---|---|---|---|---|
| | | | | ធ្នាប់ = | ០ម ០២ |
| | | | ចំអាម = | ១២ ” = | ០ម ២៥ |
| | | ហត្ថខាតហ្វង = | ២ ” = | ២៤ ” = | ០ម ៥០ |
| | ព្យាម = | ៤ ” = | ៨ ” = | ៩៦ ” = | ២ម ០០ |
| សិន = | ២០ ” = | ៨០ ” = | ១៦០ ” = | ១៩២០ ” = | ៤០ម ០០ |
| យោជន៍ = | ៤០០ ” = | | ប្រហែល | | = ១៦ គីឡូម៉ែត្រ |

ហាត់ មាត់ ទទេ– ក្នុង ១ ចំអាម មានប៉ុន្មានធ្នាប់? ប្រហែលប៉ុន្មានសង្ទីម៉ែត្រ ក្នុងខ្នាតខ្មែរ រង្វាស់ណាជាប្រធាន? ប៉ុន្មានហត្ថខាតហ្វងទើបបាន ១ ម៉ែត្រ ប៉ុន្មានព្យាម ទើបបាន ១០ ម៉ែត្រ?

ចំណោទ្យ– ១) ខ្សែ ១ បណ្ដោយប្រវែង៨ ព្យាម ៤ ហត្ថ ៥ ចំអាម ។ តើខ្សែនោះប្រវែងប៉ុន្មានម៉ែត្រ? ។

២) ថ្នល់មួយបណ្ដោយ ៥០ គីឡូម៉ែត្រ ។ តើថ្នល់នោះបណ្ដោយប៉ុន្មានព្យាម ប៉ុន្មានសិន ប៉ុន្មានយោជន៍ ។

# កុមារដ្ឋាន

## គណិត

### មេរៀនទី ១.– ចំនួនពី ២០ ដល់ ២៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន

របស់សំរាប់បង្រៀន.– បង្កើះបាច់ ។ បង្កើះរាយ ប្រាក់កាក់ ១០ សេន និងលុយសេន

របៀបបង្រៀន.-

១– បញ្ជាក់អំពីចំនួនដល់ ១៩

២- រៀនចំនួន ២០ លើកបង្កើះ ១៩ បង្ហាញសិស្សហើយថែមបង្កើះ ១ ទៅទៀត ពន្យល់ឬសួរសាកឲ្យឃើញថាត្រូវជា ២០

៣– គ្រូសរសេរចំនួន ២០ នៅលើក្តារខៀន ពន្យល់របៀបសរសេរចំនួន ២០ ឲ្យសិស្សសរសេរចំនួននោះនៅលើក្តារខៀនរួចនៅលើក្តារធ្នួន

៤- បង្រៀនចំនួន ២១, ២២, ២៣ .... ២៩ តាមរបៀបខាងលើនេះ

៥– សាបញ្ជាក់ឡើងវិញ ។

៦– ការហាត់គិតមាត់ទទេ ។

៧– ការហាត់សរសេរ ។

មេរៀនទី ២.– ចំនួនដល់ ២៩. លេខបូកឥតត្រាទុក

របៀបបង្រៀន.–

១– ការហាត់គិតមាត់ទទេ - ឲ្យសិស្សរាប់របស់បន្ទែមមួយៗ ពីរៗ បីៗ បួនៗ ពី ១ ដល់ ២៩

២– ពន្យល់របៀបធ្វើលេខបូក

៣– សិស្សធ្វើលេខបូកនៅលើក្ដារខៀន

៤– ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន

មេរៀនទី ៣.– ចំនួនពី ៣០ ដល់ ៣៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ៤.– ចំនួនដល់ ៣៩ - លេខសងឥតត្រាទុក

មេរៀនទី ៥.– ចំនួនដល់ ៣៩– មេលេខគុណទី២ ទ្វេគុណ

មេរៀនទី ៦.– ចំនួនដល់ ៣៩– ចែកចំនួនជាពីរ ពាក់កណ្ដាល

## វង្វាស់វង្វាល់

មេរៀនទី ១:.- អំពីរង្វាស់ដេស៊ីម៉ែត្រ (ដ.ម)

របស់សំរាប់បង្រៀន.– ម៉ែត្របត់ ដេស៊ីម៉ែត្រក្រោះ បង្កឹះ ប្រវែង ១ ដ.ម. – ២ ដ.ម. – ៤ ដ.ម. ។

របៀបបង្រៀន.–

១– សួរសាកបញ្ជាក់អំពីម៉ែត្រ

២– នាំសិស្សពិនិត្យមើលម៉ែត្រ ឃើញចែកជា ១០ ចំណែកស្មើគ្នា

៣– គ្រូគូសគំនូសប្រវែង ១ ដ.ម. នៅលើក្ដារខៀន

៤– នាំសិស្សពិនិត្យមើលប្រវែង ១ ដ.ម.

៥– ឲ្យសិស្សគូសបន្ទាត់ប្រវែង ១ ដ.ម. នៅលើក្ដារជ្ជួនហើយ រាស់បញ្ជាក់

៦ នាំសិស្សហាត់ស្ទាបបណ្ដាយរបស់ដែលមានប្រវែង ២ ដ.ម. ៤ ដ.ម. ។

៧– ការហាត់គិតមាត់ទទេ ផ្ទេរពីម៉ែត្រទៅជាដេស៊ីម៉ែត្រ ពីដេស៊ីម៉ែត្រទៅជាម៉ែត្រ ។

មេរៀនទី ២.– អំពីរង្វាស់សន្ទីម៉ែត្រ (ស.ម.)

មេរៀនទី ៣.– អំពីរង្វាស់មីលីម៉ែត្រ (ម.ម.)

សុំមើលតាមរបៀបខាងលើនេះមានសព្វគ្រប់ស្រាប់ ។

## បរិវច្ឆណាដ្ឋាន

**ឥព្វឥ**

មេរៀនទី ១.– ចំនួនពី ២០០ ដល់ ៣០០

ការរៀនកប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ២.– ចំនួនដល់ ៣០០– លេខបូកនឹងលេខសង

មេរៀនទី ៣.– ចំនួនពី ៣០០ ដល់ ៤០០

ការរៀនកប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ៤.– ចំនួនដល់ ៤០០–រៀនមេលេខគុណ (មេ ៣-៤-៥)

មេរៀនទី ៥.– ចំនួនពី ៤០០ ដល់ ៥០០

ការរៀនកប់ រៀនមើល រៀនសរសេរចំនួន

មេរៀនទី ៦.– ចំនួនដល់ ៥០០– រៀនគុណចំនួននឹង ៣-៤-៥

មេរៀនទី ៧.– ចំនួនដល់ ៥០០–រៀនចែកចំនួនជា ៣-៤ ៥

សុំមើលតាមរបៀបបង្រៀនរៀបចំជាគំរូ ក្នុងទស្សនាវដ្តីលេខ ១ របៀបបង្រៀនមើល រៀនសរសេរ រៀនកប់ចំនួន នឹងរបៀបបង្រៀនធ្វើលេខ

### រង្វាស់រង្វាល់

ក្នុងខែនេះត្រូវបង្រៀនសិស្សឲ្យស្គាល់ រង្វាស់-រង្វាល់ ក្នុងទម្ងន់

ដែលធំជាង រង្វាស់-រង្វាល់ ជាប្រធាន១០ដង គឺដេកាម៉ែត្រ ដេកាលីត្រ ដេកាក្រាម ហើយត្រូវបង្ហឹកសិស្សឲ្យចេះស្មានចេះប្រើប្រាស់ផង ។

សូមជូនរបៀបបង្រៀនខាងក្រោមនេះជាគំរូ

មេរៀន.- អំពីដេកាម៉ែត្រ

របស់សំរាប់បង្រៀន.- ម៉ែត្រ - ប្រវាក់ប្រវែង១០ម៉ែត្រ

របៀបបង្រៀន.- នាំសិស្សទៅកណ្ដាលទីធ្លា

១- ឲ្យវាស់នឹងម៉ែត្រ ចំនួនប្រវែង១០ម

២- ប្រាប់ឬសួរសាកសិស្សឲ្យឃើញថាប្រវែង១០ម ហៅថាមួយដេកាម៉ែត្រ សរសេរកាត់ ១ដា.ម ។

៣- នាំសិស្សពិនិត្យមើលបណ្ដោយ ១០ម នោះឲ្យច្បាស់

៤- ឲ្យវាស្មានប្រវែង១០ម ២ដា.ម ហើយវាស់បញ្ជាក់នឹងប្រវាក់ដេកាម៉ែត្រ

៥- ការហាត់គិតមាត់ទទេ - សួរសាកអំពីដេកាម៉ែត្រ ហើយរៀនគិតផ្ទេរពីម៉ែត្រទៅជា ដា.ម. ពីដា.ម. ទៅជាម៉ែត្រវិញ

៦- ការហាត់សរសេរក្នុងសៀវភៅ សុំតែងការហាត់នេះឲ្យសព្វគ្រប់ផង

មេរៀនទី ២.- អំពីប្រវាក់ ១ ដេកាម៉ែត្រ

របស់សំរាប់បង្រៀន.- ប្រដាប់១ជា,ម. នឹងម៉ែត្របត់

របៀបបង្រៀន -

១- សួរសាកអំពីដេកាម៉ែត្រដែលបានរៀនពីថ្ងៃមុន

២- នាំសិស្សពិនិត្យមើលរូបភាពប្រដាប់ដេកាម៉ែត្រ ក្នុង១ម មាន ប៉ុន្មានកំណាត់ មានអ្វីជាសំគាល់ ក្នុង៥ម មានអ្វីជាសំគាល់

៣- ការហាត់ស្មាន

៤ ការហាត់គិតមាត់ទទេ

៥- ការហាត់សរសេរនៅក្នុងសៀវភៅ

---

ថ្នាក់អាទិកដ្ឋាន

## វិទ្យាសាស្ត្រ

អាទិត្យទី ១- **អំពីសត្វព្រៃ**

យើងពុំអាចនាំសិស្សទៅបង្ហាញសត្វព្រៃរស់បានទេ ដូច្នេះគ្រូត្រូវរក ផ្ទាំងគំនូរណាដែលមានរូបសត្វព្រៃ ដើម្បីពន្យល់សិស្សឲ្យជាក់លាក់ ៗ

មេរៀនទី ១- មានសត្វខ្លះមានប្រយោជន៍ដល់មនុស្សណាស់ គេ ត្រូវតែចិញ្ចឹមវាដូចជាគោ-ក្របី-សេះ-ពពែ-ចៀម ។ល។ មានសត្វខ្លះ

ទៀតជាសត្វចង្រៃ វាតែងតែបំផ្លិចបំផ្លាញដំណាំដាំដុះអ្នកស្រុក ជួនកាលវាខាំសត្វស្រុកឬមនុស្សទៀតផង ។ សត្វព្រៃដែលសាហាវជាងគេគឺខ្លាធំនិងខ្លារខិន ។ ខ្លាមានជើងបួន គឺជាសត្វចតុបាទ ។ វាស៊ីសាច់នៅជាអាហារ គេហៅថាមំសាហារសត្វ ។ ក្រចកវាខ្ទុបចុះក្រោម (ស្រួចលិបចូល-ចេញបានតាមចិត្ត) ឯក្រចកនេះសម្រាប់ចាប់ក្រញាំសត្វជាអាហារ ។ ធ្មេញខ្លាស្រួចហើយវែង ។ ខ្លួនវាកងទន់ភ្លន់ប៉ុន្តែរហ័សណាស់ ។

អាទិត្យទី ២ - អំពីពស់

ប្រដាប់សម្រាប់បង្រៀន.- គ្រូត្រូវរកពស់ត្រាំស្រាដាក់ក្នុងកែវមកពន្យល់សិស្ស បើគ្មានដូច្នេះទេ គ្រូរកផ្ទាំងគំនូរដែលមានរូបទីឃសត្វ ។ ទីឃសត្វគឺជាសត្វមានឈាមត្រជាក់ ។ ខ្លួនវាគ្មានរោមនិងស្លាបទេ មានតែស្រកាពាសពេញជុំវិញខ្លួន ហើយលូនលើដី ។ ពស់គ្មានជើងទេ ។ ពស់សម្លាប់អន្ទុបគ្មានពិសទេ ។ ខ្លះមានពិសចឹកស្លាប់ដូចជាពស់វែកជាដើម ។ ពស់ថ្លាន់គ្មានពិសទេ ប៉ុន្តែវាអាចរឹតមនុស្សស្លាប់បានដោយងាយ ដោយសារខ្លួនវាធំហើយខ្លាំងផង ។ ពស់សកតាមរដូវវា ។

## អាទិត្យទី ៣– ការបរបាញ់

នៅស្រុកខ្មែរ នេសាទុបករណ៍សំរាប់បរបាញ់ គេច្រើនប្រើស្នា-ធ្នូ-ព្រួញ-ម្ពូរ-អន្គប់-ដង់-បន្ទឹង ។ល។

ដើម្បីនឹងចាប់សត្វ ឬសម្លាប់សត្វ គេត្រូវទាក់បាញ់ ឬដាក់ថ្នាំបំពុល ។ សត្វដែលគេយកសាច់វាធ្វើអាហារ គឺឈ្លូស-ក្តាន់-រមាំង-ប្រើស ។ល។ សត្វទាំងអស់នេះ មិនត្រឹមតែយកសាច់វាធ្វើអាហារប៉ុណ្ណោះទេ គេថែមទាំងយកស្នែងនិងស្បែកវាទៀតផង ។ គេបាញ់ដំរីយកភ្លុកវា ឯចំណែកឆ្អឹងវាគេយកមកធ្វើថ្នាំក៏បាន ។

## អាទិត្យទី ៤- អំពីការនេសាទ

នេសាទុបករណ៍ ៖ អួន - មង - សំណាញ់ - អញ្ចាង - ឆ្នុក - គន-អង្រុត - លប - ទ្រូ - សៃយុឹន ។ល។

នៅនគរខ្មែរកន្លែងនេសាទត្រីធំបំផុត គេច្រើនធ្វើនៅទន្លេសាប ។ ក្នុងមួយឆ្នាំ ៗ តែដល់ខែមីនា មានចិន-យួន-ចាម-ខ្មែរជាច្រើន ទៅតាំងទីកន្លែងនៅមាត់បឹងទន្លេសាប តាមធម្មតាគេធ្វើផ្ទះខ្ពស់ ៗ នៅក្នុងទឹក នៅជិតផ្ទះនោះគេធ្វើរានសំរាប់ហាលត្រីផង ។

របៀបធ្វើនេសាទ គេច្រើនធ្វើតាមបែបបុរាណ នៅក្នុងទឹកគេ

ហោះបង្គោលឈើតូច ៗ ជាច្រើន ប្រយោជន៍នឹងទាំងកំទេចកំទីដែលអណ្តែតទឹកមក ហើយនឹងឲ្យត្រីមកនៅផង គេយកព្រួលឬស្សីទៅព័ទ្ធជុំវិញកន្លែងនោះ រួចហើយអ្នកនេសាទដងត្រីនោះនឹងថ្នង អ្នកនេសាទខ្លះច្រើមង ៗ ក្នុងមួយថ្ងៃគេលើកមួយដងឬពីរដង មុននឹងលើកគេវាយទឹកដេញត្រីនឹងបន្ទះឬស្សី ៗ

តាមស្ទឹងអ្នកនេសាទ ច្រើនដាក់ឆ្នុកធ្វើនឹងឬស្សីពាំងនៅមាត់ស្ទឹង គេដាក់មែកឈើជាច្រើន នៅកន្លែងណាដែលគេធ្វើនេះ ហាទប្រយោជន៍ឲ្យត្រីមកនៅ រួចស្រេចហើយទើបគេពាំងឆ្នុកខាងក្រោម ឯឆ្នុកនោះមានបីចំណែក ចំណែកមួយគេហៅថាព្រួលធ្វើនឹងបន្ទោះឬស្សី ចំណែកមួយទៀតហៅថាប្រុា គឺជាប្រដាប់ចាប់ត្រីចំហានៅជិតព្រួល ចំណែកទីបីហៅថាសឹងនៅជិតប្រុា គឺដាក់កន្លែងដាក់ត្រី ដល់រដូវទឹកស្រកត្រីចុះតាមទឹកមក លុះទើសនឹងព្រួលវាហែលចូលទៅក្នុងប្រុា ៗ

ឯត្រីដែលចាប់បានមក គេយកមកធ្វើត្រីងៀត, ត្រីឆ្អើរ, ប្រហុក, ទឹកត្រី, ប្អុក, ខ្លាញ់នឹងការផង ៗ

គេនាំត្រីងៀតទៅលក់ច្រើននៅស្រុក (សិង្ហបុរី) សង្គបុ ហើយនឹងប្រទេសចិន ៗ

---

ថ្នាក់អាទិកដ្ឋាន

## វិធីបង្ការរោគ

### អាទិត្យទី ១– ជម្ងឺភ្នែក

ជម្ងឺភ្នែកមានពីរយ៉ាង ៖ ជម្ងឺភ្នែកមានខ្ទុះហូរចេញនិងជម្ងឺភ្នែកឡើងបាយ ។ ជម្ងឺភ្នែកមានខ្ទុះហូរចេញមានលក្ខណៈយ៉ាងណា ត្របកភ្នែកហើម តែភ្នែកក្រហមមានខ្ទុះហូរចេញជានិច្ច ភ្នែកឡើងជាសមើលអ្វីមិនច្បាស់ ជម្ងឺភ្នែកឡើងបាយមានលក្ខណៈបែបណា បែកគ្នានឹងជម្ងឺភ្នែកមានខ្ទុះដែរ តែនៅខាងក្នុងត្របកភ្នែកមានឡើងបាយដុំតូច ៗ ។

ដុំនេះទុកយូរទៅនឹងកើតជាដំបៅដោយរោមភ្នែកដូត ៗ ត្រូវដាក់ថ្នាំកុំបណ្ដោយទុំនោះទៅភ្នែកនឹងខូច ។

### អាទិត្យទី ២– ការថែរក្សាភ្នែក

កុំពាល់ភ្នែកនឹងម្រាមដៃ ត្រូវចៀសវាងកុំឲ្យប៉ះទង្គិចនឹងអ្វី កុំឲ្យត្រូវខ្យល់ ធូលីឬផ្សែង ។ ត្រូវខ្វាចពន្លឺចាំងខ្លាំងដោយកុំមើលថ្ងៃ ។ ត្រូវដាក់សៀវភៅមើលចម្ងាយ ៣០ ស.ម. ពីភ្នែក ។ បើភ្នែកឡើងក្រហមត្រូវលាងនឹងទឹកក្ដៅ បើពុំជាត្រូវទៅរកពេទ្យមើលកុំបណ្ដោយ ។

មេរៀនសង្ខេប– ជម្ងឺភ្នែកនេះឈឺយឺតណាស់ ប៉ុន្តែគង់នឹងបណ្តាលឲ្យខ្វាក់បានដូចជាជម្ងឺភ្នែកដែលមានខ្ទុះហូរចេញនោះដែរ មុនដំបូងភ្នែកចាញ់ពន្លឺថ្ងៃណាស់ចេះតែហូរទឹកភ្នែក ខាងត្របកមានឡើងបាយដុំតូច ៗ ដូចជាគ្រាប់បាយគេមើលឃើញគ្រាប់បាយនោះជាក់ច្បាស់ដោយត្រឡប់ត្របកភ្នែកខាងក្នុងចេញមកក្រៅ ដល់ត្របកភ្នែកត្រឡប់ចូលទៅក្នុងវិញ រោមភ្នែកដុតគ្រាប់បាយនោះហើយក៏កើតជាដំបៅ ដល់ក្រោយមកភ្នែកឡើងពណ៌ប្រផេះហើយក៏មើលលែងឃើញសោះ ។

ហេតុដូច្នេះតែកាលណាមានជម្ងឺឈឺភ្នែកនេះហើយត្រូវស្វពន់រកថ្នាំថែទាំជាប្រញាប់ ឯថ្នាំទៀតត្រូវរកតែថ្នាំណាដែលធ្វើដោយមានក្បួនខ្នាតត្រឹមត្រូវ បូរកុំទុកភ្នែកឲ្យឈឺហួសការហើយទើបទៅរកគ្រូពេទ្យឲ្យមើលនោះ ។

## អាទិត្យទី ៣ – ការថែរក្សាត្រចៀក

ត្រូវជូតស៊ិកត្រចៀកឲ្យស្អាតជានិច្ច បើទឹកចូលត្រចៀកត្រូវប្រញាប់ត្បារចេញឲ្យអស់តែទុកនឹងបណ្តាលឲ្យកើតជាអំបៅអំបែកខួចត្រចៀក កុំត្បារត្រចៀកនឹងរបស់រឹងព្រួចខ្លាចជ្រុលដៃនាំឲ្យធ្លាយក្រដាសត្រចៀកឬកោសដាច់សាច់ខាងក្នុង ត្រូវប្រើសំឡីក្នុងការត្បារត្រចៀកដោយផ្សើមទឹកអប់បន្តិច ៗ ផង ( ទឹកកូឡូញ )

អាទិត្យទី៤- រៀនសារដើមឡើងវិញ

---

បរិច្ឆណដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី ១- ១ អំពីអាហារ

របស់សំរាប់បង្រៀនៈ អង្ករ មេក្រៅនំបុ័ង នំបុ័ង ៗ នាំសិស្សនិយាយ តោទសួរឲ្យឆ្លើយដូចមានរបៀបខាងក្រោមនេះ ៗ

អ្នកបរិភោគអ្វីជាអាហារ ? ជាតិណាខ្លះបរិភោគបាយដូចយើង ៗ បារាំងបរិភោគបាយដូចយើងដែរឬទេ ? ជាតិណាខ្លះដែលអាស្រ័យនំបុ័ង? គេចំអិនបាយដូចម្តេច ? នំបុ័ងយ៉ាងដូចម្តេច ? បើស៊ីបាយទទេបានឬទេ? ឯងអាស្រ័យបាយនឹងអ្វីខ្លះ ?

### ២- អំពីបន្លែ

របស់សំរាប់បង្រៀនៈ ប៉េងប៉ោះ ត្រប់ ជីរ សាឡាត់ ដំឡូង ផ្លែឈើអ្វីទៅទៀត ៗ ឲ្យសិស្សរកម្នាក់មួយមុខៗ បន្លែឯទៀត ៗ

ពាក្យសួរ.- យើងបរិភោគបន្លែណាខ្លះ ឲ្យសិស្សម្នាក់ចាំបង្ហាញ

បន្លែមួយៗ ។ បន្លែណាខ្លះដែលគេបរិភោគស្រស់ឆ្អិន ? អន្លក់គេបរិភោគដូចម្តេច ? អ្វីខ្លះដែលយើងបរិភោគជាអន្លក់ ។ ( ស្លឹកពង សាឡាត់ ជីរ ខាត់ណា ។ល។ ) នៅក្នុងដំឡូងមានជាតិអ្វីខ្លះ ? (កាប់ដំឡូងឆ្អិនមួយឲ្យសិស្សមើលជាតិម្សៅ) ។ បន្លែណាទៀតដែលជាជាតិម្សៅ ? ផ្លែឈើណាខ្លះដែលយើងបរិភោគជារាល់ថ្ងៃជាអាហារ ?

អាទិត្យទី ២– ១– អំពីត្រី

ឲ្យសិស្សរកត្រីស្រស់ – ត្រីងៀតត្រីឆ្អើរ ផ្អក ប្រហុក ។

ពាក្យចោទ. គេយកត្រីមកចំអិនធ្វើបានម្ហូបអ្វីខ្លះ ? បើទុកឲ្យបានយូរគេយកត្រីទៅធ្វើដូចម្តេចខ្លះ? គេប្រឡាក់ឆ្អើរត្រីដូចម្តេច ? ។ល។ គេបរិភោគប្រហុករបៀបដូចម្តេច ? ។

២– សត្វស្រុកដែលគេយកសាច់ជាអាហារ

របស់សំរាប់បង្រៀន សាច់ជ្រូក សាច់គោ សាច់ក្របី សាច់មាន់ ។ល។

អាទិត្យទី ៣– ១ សត្វព្រៃដែលគេយកសាច់ជាអាហារ

២– ទឹកដោះគោ

របស់សំរាប់បង្រៀន ទឹកដោះគោឆៅ ខ្លាញ់ប៊ឺរ ប្រូម៉ាស (បើមាន)

អាទិត្យទី ៤– អំពី ស៊ុត (ពង)

សូមគ្រូតែងពាក្យសួរផងចុះ

បរិច្ឆណាដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១– ១ ត្រូវបរិភោគល្មមសមគួរ ៗ មើលក្នុងសៀវភៅ វិធីបង្ការរោគទំព័រ ២៤

២– ត្រូវបរិភោគអាហារដែលល្អឥតទោស

អាទិត្យទី– ១ ត្រូវបេះផ្សំចំណីអាហារ

២ ត្រូវចំអិនសាច់ទឹកអាហារឲ្យល្អ ៗ

អាទិត្យទី-៣– ៤ ត្រូវបរិភោគតាមសំរួលហើយទំពាឲ្យល្អិតផង ៗ

សូមគ្រូមើលក្នុងសៀវភៅវិធីបង្ការរោគចុះ ៗ

---

កុមារដ្ឋាន

## វិត្តស្វាធ្យាយន៍

អាទិត្យទី១– អំពីខ្លួនមនុស្ស

គ្រូចាត់សិស្សម្នាក់ឲ្យទៅឈរនៅមុខសិស្សឯទៀត សួរហើយឲ្យ

សិស្សម្នាក់ៗ ចង្អុលប្រាប់សិស្សតាំងឡាយថា នេះហៅក្បាល? នេះលលាដ៍ក្បាល ។ល។ ត្រូវឲ្យសិស្សម្នាក់ៗ ស្ទាបក្បាលលលាដ៍ក្បាលខ្លួនឯងរៀងពល់គ្នា ។ ល ។

ពាក្យសួរ– ឯណាក្បាល? ក្បាលភ្ជាប់នឹងដងខ្លួនដោយអ្វី? សក់ដុះនៅឯណា? សក់ក្មេងពណ៌ដូចម្ដេច? ចុះសក់មនុស្សចាស់វិញ? នៅលើមុខមានអ្វីខ្លះ? (ឲ្យសិស្សចង្អុលគ្រប់ ៗ គ្នា) ភ្នែកសម្រាប់ធ្វើអ្វី? ចិញ្ចើមនឹងរោមភ្នែកមានប្រយោជន៍ដូចម្ដេច? ច្រមុះសម្រាប់ធ្វើអ្វី? នៅក្នុងមាត់មានអ្វី? យើងស្ដាប់យើងឮដោយសារអ្វី? ។ ល ។

## អំពីដងខ្លួន

គ្រូឲ្យសិស្សម្នាក់ទៅឈរនៅមុខសិស្សឯទៀត ហើយឲ្យដោះអាវចេញ ទើបលោកគ្រូចង្អុលអវយវៈផ្សេងៗ ។

ពាក្យសួរ– ឯណាហៅដងខ្លួន ។ ដងខ្លួនខាងលើហៅថាអ្វី? ខាងក្រោមហៅថាអ្វី? ឯណាឆ្អឹងជំនីរ? ឯណាឆ្អឹងខ្នង? យើងពត់ខ្លួនបានទៅខាងណាខ្លះ? ដោយហេតុអ្វី? ឆ្អឹងខ្នងយើងមិនមែនជាឆ្អឹងមួយដុំវែងនោះទេ? គឺជាឆ្អឹងកំណាត់ខ្លីៗ ត្រួតៗ លើគ្នា ហេតុនេះហើយបានជាយើងពត់ខ្លួនទៅខាងណាក៏បាន ។ នៅក្នុងទ្រូងមានអ្វីខ្លះ? បើមានផ្ទាំងគំនូរត្រូវយកមកបង្ហាញសិស្សឲ្យស្គាល់ សួត បេះដូង ហើយនឹងក្រពះ ពោះវៀន ថ្លើម ប្រមាត់ ដែលនៅក្នុងពោះមើលពុំឃើញ )

អាទិត្យទី ២- ១ អវយវៈលើក្រោម

សូមគ្រូធ្វើតាមរបៀបមុន ៗ ចង្អុលបង្ហាញសិស្ស ឯណាហៅថាដៃ ដើមដៃ កែងដៃ កំភួនដៃ កដៃ បាតដៃ ខ្នងដៃ ម្រាមដៃ ថ្នាំងដៃ ក្របក ជើង ភ្លៅ ជង្គង់ កំភួនជើង កជើង កែ្ងកគោ កែងជើង បាតជើង ខ្នងជើង ម្រាមជើង ។

សូមគ្រូពន្យល់ប្រយោជន៍នៃសន្ទាក់ដៃជើងនិមួយ ៗ ឲ្យសិស្ស ឃើញច្បាស់ ។

២ ភ្នែក

អាទិត្យទី ៣- ១ គ្រាបៀក - ២ ប្រមុះ ។

អាទិត្យទី ៤- ១ អណ្ដាត - ២ ស្បែក ។

---

កុមារដ្ឋាន

វិធីបង្ការរោគ

អាទិត្យទី ១- ការបើរក្បូសក់

សូមគ្រូបង្រៀនតាមសៀវភៅវិធីបង្ការរោគទំព័រ ៤៣

អាទិត្យទី ២- ត្រូវធ្វើកុំឲ្យមានចៃ

សូមមើលក្នុងសៀវភៅដដែលទំព័រ ៤៦

## អាទិត្យទី ៣ – ត្រូវមើលជម្ងឺកមរមាស់

ជម្ងឺកមរមាស់ពុំដែលជាឯងទេ ហេតុដូច្នេះត្រូវតែមើលដូចតាមរបៀបខាងក្រោមនេះ ៖

ត្រូវដុសខ្លួននឹងសាប៊ូខ្មៅ ដុសក្អួតនឹងសាប៊ូខ្មៅឲ្យយ៉ាងខ្លាំង កមនេះនឹងបែកហើយមេរោគអាត់នឹងពងអាត់របើកចេញពីរន្ធ រួចត្រូវងូតទឹកដុសសាប៊ូលាបថ្នាំស្ពាន់ធ័រ ទុកមួយថ្ងៃទើបងូតទឹកក្តៅលាងខ្លួនចេញ ។ បើនៅមានមេអាត់ទៀតត្រូវធ្វើឡើងវិញម្តងទៀត ។

ត្រូវស្ងោរខោអាវឲ្យស្អាតហើយដេកលើកំព៉លស្អាត ។

## អាទិត្យទី ៤ – សាបម្រៀនឡើងវិញ ។

---

# លោកនីតិ

## សំរាប់គ្រូបង្ហាត់

## អំពីសំបុត្រកំណើត

សំបុត្រកំណើតមានប្រយោជន៍ណាស់ ហេតុនេះត្រូវកុំធ្វេសប្រហែសឲ្យសោះ បើមានកូនកើតរវាងបីថ្ងៃត្រូវរកសាក្សីបានពីរនាក់ហើយនាំគ្នាទៅសាលាឃុំប្តឹងសុំចុះកំណើតកុមារនោះ ហើយត្រូវសុំចម្លង

កំណើតមួយច្បាប់ទុកប្រើការទៅថ្ងៃក្រោយដូចចូលទៅរៀនក្នុងសាលា ឬ បង់ការ ឬ បួសឬទាស់ទែងគ្នាដល់តុលាការអំពីបម្យាប់មតិកក្ដី ត្រូវមានផាតិសញ្ញាប័ត្រដ៏ពាប ។

បើនៅក្រុងភ្នំពេញ កាលណាមានកូនកើតត្រូវទៅប្ដឹងមេសង្កាត់ (មេឃុំ) ក្នុងពេលដែលកើតនោះទើបមេឃុំចេញសំបុត្រមួយឲ្យគាន់យកទៅមន្ទីរពេទ្យបារពេត ដើម្បីឲ្យពដការការពារពេតទៅបណ្ដុះអុតកុមារនោះភ្លាមរួចបាននាំទៅចុះកំណើតត្រូវធ្វើដូចម្ដេច ? នៅភ្នំពេញគេធ្វើដូចម្ដេចទៀត ? បើមិនបានទៅប្ដឹងមេឃុំឲ្យចុះកំណើតទេនោះនឹងមានទោសដូចម្ដេច ? ( លក់ពិន័យ ) សំបុត្រកំណើតមានប្រយោជន៍យ៉ាងដូចម្ដេចខ្លះ ? ។

## សំបុត្រអាពាហ៍ពិពាហ៍ (អាវាហវិវាហ)

មុននឹងរៀបការកូនប្រុស - ស្រី ត្រូវមាតាបិតាខាងកូនស្រី ទៅប្ដឹងមេឃុំចំនួន ៨ ថ្ងៃមុនរៀបមង្គលនេះ មេឃុំត្រូវចេញសំបុត្រមួយច្បាប់ មានចុះឈ្មោះស្វាមីខ្លួនប្រុស ស្រី ហើយបញ្ជាក់ថា បើឈ្មោះណាមានទាក់ទងនឹងនាងនេះ នឹងអ្នកនេះ ត្រូវប្ដឹងតវ៉ាក្នុងរវាង ៨ ថ្ងៃមុននឹងរៀបអាវាហវិវាហតែបើហួសកំណត់ថ្ងៃនេះហើយនឹងទុកជាស្រេច លុះរៀបអាពាហ៍ពិពាហ៍ស្រេចហើយ មាតា - បិតានឹងកូនប្រុស - ស្រីមានសាក្សី

ពីរនាក់ នាំគ្នាចុះអេតាស៊ីវិលនៅសាលាឃុំឬសុំសំណៅមួយសន្លឹកទុកប្រើការទៅពេលក្រោយ ពីព្រោះមានច្បាប់បញ្ញត្តថា នរណាយកគ្នាជាប្តីប្រពន្ធពុំបានចុះអេតាស៊ីវិលនោះមិនពេញជាប្តីប្រពន្ធទេ បើមានហេតុទាស់ទែងលែងលះគ្នានោះ តុលាការមិនទទួលបណ្តឹងឡើយ បដិសេធចោលជាអសារឥតការ ។

មរណភាព

របៀបកើតនឹងស្លាប់មិនប្លែកគ្នាប៉ុន្មានទេ នៅទីក្រុងបើមានស្លាប់គេទៅប្តឹងសុំសំបុត្រមេឃុំឬយកសំបុត្រនោះទៅមន្ទីរការការពេត ដើម្បីឲ្យគ្រូពេទ្យទៅពិនិត្យមើលខ្មោចនោះ តើស្លាប់ដោយរោគអ្វី ។ លុះពេទ្យពិនិត្យមើលត្រឹមត្រូវហើយ ទើបអនុញ្ញាតឲ្យយកខ្មោចនោះទៅកប់ឬបូជាតាមកំណត់ពេលវេលា ដែលគ្រូពេទ្យបានបញ្ញត្តក្នុងសំបុត្រនោះស្រាប់ ។ រួចពីនោះមកបីថ្ងៃទើបបានគេនាំគ្នាទៅចុះមរណភាពឯសាលាឃុំដូចជាចុះកំណើតនោះដែរ ។

## មេរៀនត្រាប់មាត់

សំរាប់គ្រូបង្ហាត់

## ១– ត្រូវគោរពជីតាជីដូនអ្នក

ជីដូនជីតា បីបាច់រក្សា ឪពុកម្ដាយអ្នក ស៊ូទ្រាំលំបាក ជួនមានគ្រោះថ្នាក់ តែមិនទំលាក់ ចាត់ការថែទាំ ។ អ្នកៈគិតកាលណា ជីដូនជីតា រក្សាថ្នាក់ថ្នម ដរាបអ្នកធំ ចំរើនវ័យព្រាម ចូរអ្នកថ្នាក់ថ្នម ថែទាំប្រតិបត្តិ ។

ពាក្យពន្យល់ –

វ័យៈ អាយុ, កំណត់អាយុ

## ២– ត្រូវទំនុកបំរុងគ្នាទៅវិញទៅមក

នាងអើយចូរអ្នក ចាំទុកឲ្យជាក់ ទាំងប្រុសទាំងស្រី លោកថានៅផ្ទះ ម៉ែឪទទៃ កាលណាទៅព្រៃ ម៉ែឪជាមួយ ។ ចូររក្សាគ្នា ថែទាំការពារ កុំឲ្យមានព្រួយ កុំទាស់ទែងគ្នា មករៀនជាមួយ នាំឲ្យមានព្រួយ ដល់ម៉ែឪអ្នក ។

## ៣ - ចិត្តអំណត់

ខឹងនាំតែខាត ខឹងខុសសុទ្ធសាធ បង្កទុក្ខភ័យ បង្កើតទុច្ចរិត នាំចិត្តអប្រិយ ពុំផលប្រពៃ ពីព្រោះតែខឹង ។ ចូរក្មេងទាំងឡាយ ជៀសវាងឲ្យឆ្ងាយ អំពីកំហឹង កាន់ចិត្តអំណត់ ទ្រាំអត់ឲ្យនឹង ទើបអ្នកបានដឹង

ផលនៃអំណាត់ ។ ធម្មតាមនុស្សស្លូត បានសុខរហូត ពុំសូវក្រខ្សត់
តាំងចិត្តឲ្យល្អ បវរបរិសុទ្ធ បានជួងៈកផុត អំពីអន្តរាយ ។

ពាក្យពន្យល់ -

សុទ្ធសាធ ( ម.ថ សុត-ធាត ) គ្រប់ព្រម, តាំងគ្រប់ ។
អប្រិយ= (ម.ថ អប់ប្រី ) ដែលពុំគួរស្រឡាញ់ ។ បវរបរិសុទ្ធ=
(ម.ថ ប-វ-ប-រិ-សុត ) ប្រសើរស្អាត ។

## ៤– ទោសនៃការផឹកសុរា

ស្រានាំតែស្រាលចិត្ត ប្រាសគំនិតពិកប្បការ ប្រាសចាំងផ្លូវសារក្យា
ហិនទ្រព្យកេរ្តិ៍មរតក ។ ស្រានាំបង្កើតរោគ យសថយថោកឈ្មោះគា
ក្រក់ ស្គាំងស្គមកាយទ្រមក់ បញ្ចាំលក់ស្រែចំការ ។ ផឹកហើយពុំ
ដែលស្រួល ដួនដេកដួលខ្លួនក្ដៅផ្សា ព្រហើនមហិមា ពោលវាចាខុស
ជាត្រូវ ។ ដូច្នេះគួរលះបង់ វាកចំណង់នាំអាស្រូវ ស្រានេះបើផឹកទៅ
ចិត្តមួម៉ៅកើតជានិច្ច ។

ពាក្យពន្យល់- កេរ្តិ៍មរតក= ( ម.ថ កេ-មៈ-រៈ-ដក់ ) គឺទ្រព្យ
របស់បុគ្គលដែលស្លាប់ហើយ ។ មហិមា= ( ម.ថ មៈ ហិមា )
ច្រើនក្រៃ ក្រៃកន្លង ។ វាចា= សំដី ។ អាស្រូវ= ដែលលេចឮ
សុសសាយទៅជាមិនល្អ ។

## ៤· ការប្រព្រឹត្តនៃសិស្សល្អ

សិស្សល្អតែងសំអាត កាយស្អាតបាតឥតកខ្វក់
ខោអាវតែងបោកគក់ មិនទ្រមក់ដេកហួសការណ៍ ។
តែងមានសណ្តាប់ធ្នាប់ ដោយគួរគាប់តាមចរិយា
មុនពេលទៅសាលា តែងអាត្មាដោយសមរម្យ ។
ងូតទឹកជំរះកាយ ជុំពុកម្តាយដែលជាធំ
លាលោកតាមគួរសម ហើយទើបទៅដោយស្រួសក៏ ។
តែងឃ្លាតឥតមានអាក់ រៀនក្នុងថ្នាក់គ្មានហ្មងសៅ
កាលគ្រូប្រៀនប្រដៅ សិស្សនោះនៅប្រុងផ្ទៀងស្តាប់ ។

ពាក្យពន្យល់·-

ការណ៍ = (ម·ថ ការ) ហេតុ ចរិយា = (ម.ថ ចៈ-រិ-យ៉ា)
ការប្រព្រឹត្ត ។

## ៥– វិធីបង្ការរោគ

ឯក្បួនវិធីបង្ការរោគ គឺលោកប្រដៅឲ្យបានសុខ
ជៀសវាងជម្ងឺទៅមុខ ច្បាប់នេះចាំទុកជាកុំខាន ។
ត្រូវដុសលាងសំលៀកបំពាក់ ដែលអ្នកបិទបាំងកាយប៉ុន្មាន

ហើយត្រូវសំអាតឲ្យស្អាតប្រាណ ទើបបានសេចក្ដីសុខសប្បាយ ។
ឯផ្ទះត្រូវបោសប្រាសប្រក្រតី អាហារចំណីអ្វីទាំងឡាយ
ត្រូវស្អាតទើបគ្មានរោគក្នុងកាយ ទឹងបរិភោគបាយឲ្យឆ្អែតល្មម ។
ឆ្អែតហួសព្រោះឈឺក្រពះបាយ នាំក្លាយជារោគឈឺស្គាំងស្គម
ក្រចកត្រូវកាត់ឲ្យស្អាតព្រម ចាប់ពមអាហារគ្មានក្អែលជាប់ ។
ឯទឹកយើងត្រូវផឹកទឹកថ្លា ដាំឆ្អិនដល់ការនោះទើបគាប់
ស្រះផឹកទៅពុលគ្មានគេរាប់ អាកៀនញៀនជាប់ធ្លាប់ខ្ជួបខ្ជួនៗ

ពាក្យពន្យល់ –

សំលៀកបំពាក់= ខោអាវ ។

រោគ= ជម្ងឺ ។ ក្លាយ= ប្រែប្រួល ។

ពម = បរិភោគ ។ ពុល = ដែលមានពិសបណ្ដាលឲ្យ

ក្អួតបង្អោររអ៊ប់រអើ ។

រោងពុម្ពខ្មែរ